# ជំនួយសង្គ្រោះបន្ទាប់ពីមានគ្រោះមហន្តរាយ

## សៀវភៅមគ្គុទេសក៍អំពីកម្មវិធីសំរាប់ឯកត្តជន និងគេហដ្ឋាន

*FEMA 545 / កក្កដា ២០០៨ (July 2008)*

Applicant’s Guide to the Individuals & Households Program – Khmer (Cambodian) 7/08



ទីភ្នាក់ងារគ្រប់គ្រងភាពមានអាសន្នរបស់សហព័ន្ធ (Federal Emergency Management Agency - FEMA) ស្ថិតក្រោមអំណាចនៃផ្នែក 408 នៃច្បាប់អំពីជំនួយ សង្គ្រោះបន្ទាន់ និងជំនួយសំរាប់គ្រោះមហន្តរាយរបស់ (Robert T. Stafford Disaster Relief and Emergency Assistance Act) 42 U.S.C. §5174, និងសិទ្ធិកម្មសិទ្ធិ 44 នៃបទបញ្ជារបស់ច្បាប់សហព័ន្ធ (Code of Federal Regulations -CFR) អាចផ្តល់ជំនួយហិរញ្ញ វត្ថុ និងបើចាំបាច់ ផ្តល់នូវសេវាផ្សេងៗទៀតដោយ ផ្ទាល់ទៅដល់ឯកត្តជន និងគេហដ្ឋានទាំងឡាយណាដែលមានសិទ្ធិ ទទួល ហើយដែលអ្នកទាំងនោះទទួលរងគ្រោះ ដោយផ្ទាល់ពីគ្រោះមហន្តរាយធំៗ ហើយពួកគេមាននូវការចំណាយ ចាំបាច់ និងតំរូវការខ្លាំងដែលមិនអាចធ្វើការដោះ ស្រាវបានតាមមធ្យោបាយផ្សេងៗទៀតបាន។

ជូនចំពោះ បេក្ខជនៈ

ដើម្បីជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងជាប្រចាំរបស់យើងក្នុងការផ្សព្វផ្សាយឱ្យបានច្បាស់អំពីតំរូវការ ឯកសារ និង ដំណើរការផ្សេងៗនៃកម្មវិធីសំរាប់ឯកត្តជន និងគេហដ្ឋាន (Individual and Households Program - IHP)របស់ FEMA នោះ យើងនឹងផ្តល់ជូនលោកអ្នកនូវកូនសៀវភៅនេះ ។ កូនសៀវភៅនេះ មានព័តិមានស្តីពីកម្មវិធីសំខាន់ៗ អំពី IHP ។ សំរាប់សំណួរទាំងឡាយណាដែលទាក់ទងនឹងមហន្តរាយពិសេសណាមួយ វាគឺជារឿងប្រសើរបំផុតដែល លោកអ្នកទៅមើលគេហទំព័ររបស់យើង www.fema.gov ឬ ទំនាក់ទំនងមកខ្សែទូរស័ព្ទជំនួយ (Helpline) របស់ FEMA ដែលមានលេខ 1-800-621-3362 (FEMA) (TTY 1-800-462-7585 សំរាប់អ្នក គរថ្លង់) ។

ជាការឆ្លើយតបនឹងច្បាប់ឆ្នាំ ២០០៦ស្តីអំពីកំណែទម្រង់ការគ្រប់គ្រងភាពមានអាសន្នក្រោយព្យុះកាទ្រីណា (Post Katrina Emergency Management Reform Act) FEMA កំពុងដំណើរការកែសំរួលគោលការណ៍ និងកម្មវិធីរបស់យើង ដើម្បីដាក់បញ្ចូលនូវអាជ្ញាធរថ្មីៗ ដែលសភា Congress របស់អាមេរិកបញ្ជូនមកឱ្យសហការ ជាមួយ FEMA ។ ខណៈដែលគោលការណ៍ និងនីតិវិធីនានា ត្រូវ បានគេរៀបចំរួច សៀវភៅមគ្គុទេសក៏នេះ ដែលមាន ការកែសំរួលហើយ ក៏នឹងមានចែកជូនជាសាធារណៈផងដែរ នៅលើគេហទំព័ររបស់ FEMA ក្នុងមជ្ឈមណ្ឌលស្រោច ស្រង់គ្រោះមហន្តរាយ និងតាមសំបុត្រសំរាប់បេក្ខជន ទាំងឡាយណាដែលបានដាក់ពាក្យតាមទូរស័ព្ទ ឬតាមអ៊ីធឺណិត ។

កម្មវិធីនានារបស់ FEMA ត្រូវបានគេរៀបចំឡើងដើម្បីជួយសំរួលដល់តំរូវការចាំបាច់ និងជួយដល់ឯកត្តបុគ្គល និង គេហដ្ឋានរបស់ពួកគេ ក្នុងការចាត់វិធានការដំបូងឆ្ពោះទៅរកភាពប្រសើរឡើងវិញ ។ កម្មវិធីជាច្រើនរបស់ FEMA មានបំណងចង់ឱ្យគេហដ្ឋាន ឬទ្រព្យសម្បត្តិទាំងឡាយ អាចវិលត្រឡប់មកនៅដូចស្ថានភាពមុនពេលមានគ្រោះ មហន្តរាយកើតឡើង ។

យើងរង់ចាំធ្វើជាដៃគូជាមួយលោកអ្នក ក្នុងដំណើរការស្តារឡើងវិញ ខណៈពេលដែលលោកអ្នក និងសហគមន៏ នាំគ្នា កសាងឡើងវិញបន្ទាប់ពីគ្រោះមហន្តរាយ ។

សូមទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

*នាយិកាទទួលបន្ទុកផ្នែកជំនួយគ្រោះមហន្តរាយ* FEMA

# មាតិកា


| | |
|---|---|
| ទិដ្ឋភាពទូទៅនៃកម្មវិធីសំរាប់ឯកត្តបុគ្គល និងគេហដ្ឋាន | 1 |
| ប្រភេទនៃជំនួយ | 2 |
| សិទ្ធិពលរដ្ឋ និងជំនួយសំរាប់គ្រោះមហន្តរាយរបស់អ្នក | 3 |
| ដំណើរការជំនួយសំរាប់គ្រោះមហន្តរាយ | 4 |
| សិទ្ធិស្របច្បាប់ក្នុងការទទួលយកកម្មវិធី | 6 |
| ប្រភេទនៃការខូចខាតទាំងឡាយដែលមានសិទ្ធិទទួលយកកម្មវិធី | 8 |
| ព័ត៌មានសំខាន់អំពីជំនួយសំរាប់គ្រោះមហន្តរាយ | 11 |
| បើសិនជាអ្នកមានសិទ្ធិទទួលយកជំនួយ | 12 |
| ព័ត៌មានអំពីការធានារ៉ាប់រង និងជំនួយសំរាប់គ្រោះមហន្តរាយ | 13 |
| ខ្ញុំចង់ឱ្យគេសើរើករណីរបស់ខ្ញុំឡើងវិញម្តងទៀត ( បណ្តឹងឧទ្ធរណ៍) | 15 |
| ការកសាង និងការជួសជុលឡើងវិញ – វិធានការនានាក្នុងការបន្ធូរបន្ថយ | 17 |
| ព័ត៌មានអំពីព័ត៌មានបន្ថែមទាក់ទងនឹងកម្មវិធីជំនួយសំរាប់គ្រោះមហន្តរាយ | 19 |
| សំណួរដែលគេសួរញឹកញាប់ និងចំលើយ | 24 |
| ការបរិយាយអំពីមូលហេតុនៃភាពមិនមានសិទ្ធិ | 33 |
| គំរូ -សំណុំបែបបទ៩០-៦៩B របស់ FEMA សេចក្តីប្រកាស និងការចេញផ្សាយ | 44 |
| ខ្សែទូរស័ព្ទរបស់ FEMA សំរាប់ការប្តឹងអំពីការបន្លំ | 45 |

# និដ្ឋភាពទូទៅនៃកម្មវិធីសំរាប់ឯកត្តបុគ្គល  និងគេហដ្ឋាន (IHP)

**គោលបំណង:** នៅពេលមានគ្រោះមហន្តរាយកើតឡើង **កម្មវិធីសំរាប់ឯកត្តបុគ្គល និងគេហដ្ឋាន (Individuals and Households Program - IHP)** ផ្តល់ជូនថវិកា និងសេវានានាដល់ពលរដ្ឋ ទាំងឡាយដែលស្ថិតនៅក្នុងតំបន់ដែលមានគ្រោះមហន្តរាយ នៅពេលដែលទ្រព្យសម្បត្តិរបស់ពួកគេទទួលរងការ ខូចខាត ឬ បំផ្លិចបំផ្លាញ ហើយដែលការខូចខាតទាំងនោះមិនអាចទូទាក់សងបានដោយធានារ៉ាប់រង ។

សៀវភៅមគ្គុទេសក៏ស្តីពីកម្មវិធីនេះផ្តល់នូវព័តិមាន ដែលអាចជួយលោកអ្នកឱ្យមានការយល់អំពី IHP ហើយក៏ ពន្យល់លោកអ្នកអំពីរបៀបដាក់ពាក្យផងដែរ ។ លោកអ្នក ត្រូវបំពេញគ្រប់លក្ខខណ្ឌពិសេស ទាំងអស់ ដើម្បីអាចមានសិទ្ធិ ដាក់ពាក្យស្នើសុំជំនួយ ។

IHP ត្រូវបានរៀបចំឡើងដើម្បីជួយអ្នកចំពោះការចំណាយទាំងឡាយណាដែលពិបាកដោះស្រាយ ហើយដែលមិនអាចធ្វើការទូទាត់បាន តាមមធ្យោបាយនានា ។

**ការកំរិតៈ** IHP នឹងមិនទូទាត់ការខូចខាតទាំងអស់របស់អ្នក ពីការខូចខាតចំពោះទ្រព្យសម្បត្តិរបស់អ្នក ( ផ្ទះ ទ្រព្យសម្បត្តិផ្ទាល់ខ្លួន  ទំនិញប្រើប្រាស់ក្នុងផ្ទះ) ដែលបណ្តាលមកពីគ្រោះមហន្តរាយនោះ ។

IHP មិនមានបំណងស្តារទ្រព្យសម្បត្តិរបស់អ្នកដែលខូចខាតឱ្យមានសភាពដូចមុនពេលមានគ្រោះមហន្តរាយកើតឡើងឡើយ ។ ក្នុងករណីមួយចំនួន IHP គ្រាន់តែអាចផ្តល់ទឹកប្រាក់ល្មម ត្រឹមការកំរិតរបស់កម្មវិធីសំរាប់ អ្នកដើម្បីធ្វើឱ្យរបស់មួយអាចប្រើប្រាស់បានវិញប៉ុណ្ណោះ ។

IHP មិនធ្វើការទូទាត់ដោះស្រាយចំពោះការខូចខាតទាំងឡាយណាដែលទាក់ទងនឹងជំនួញដែល ទទួលរងគ្រោះហមន្តរាយនោះឡើយ ។

តាមច្បាប់ IHP មិនអាចផ្តល់ប្រាក់ទៅអ្នកចំពោះការខូចខាតទាំងឡាយណាដែលត្រូវបានទូទាត់ដោះស្រាយការធានារ៉ាប់រងរបស់អ្នកនោះទេ ។

ខណៈដែលលុយមួយចំនួនមានសល់តាមរយៈ IHP ជំនួយសំរាប់គ្រោះមហន្តរាយភាគច្រើនដែលបានមកពីរដ្ឋាភិបាលសហព័ន្ធ គឺមានទ្រង់ទ្រាយជាប្រាក់កម្ចី ដែលបានមកពី **រដ្ឋបាលជំនួញខ្នាតតូច** (SBA) ដែលគេត្រូវតែសងវិញ។ បេក្ខជនទាំងឡាយដែលដាក់ពាក្យចំពោះកម្មវិធី IHP នឹងអាចត្រូវបានគេទាមទារឱ្យទៅស្វែងរកជំនួយពី SBA ជាមុនសិន មុនពេលគេពិចារណាចំពោះប្រភេទ ជំនួយរបស់កម្មវិធី IHP មួយចំនួន។ អ្នកមិនចាំបាច់ផ្ញើបែបបទឥណទានរបស់ SBA ដើម្បីឱ្យគេពិចារណា សំរាប់ជំនួយបង់ថ្លៃជួលរបស់ FEMA ។

# ប្រភេទនៃជំនួយ

**បញ្ជីខាងក្រោមបង្ហាញអំពីប្រភេទជំនួយដែលមានតាមរយៈ IHP ហើយនឹងអ្វីដែលប្រភេទជំនួយនិមួយៗផ្តល់ជូន។**

**ការផ្តល់ជំរកបណ្តោះអាសន្ន** (កន្លែងស្នាក់នៅមួយសំរាប់រយៈពេលកំណត់)៖ថវិកាសំរាប់ការជួលកន្លែងមួយរស់នៅ ឬ រដ្ឋាភិបាលផ្តល់កន្លែងស្នាក់នៅ នៅពេលពុំមានកន្លែងជួល។

**ការជួសជុលៈ** ថវិកាសំរាប់ម្ចាស់ផ្ទះដែលត្រូវជួសជុលការខូចខាតដែលបណ្តាលមកពី គ្រោះមហន្តរាយ ហើយដែលគ្មានធានារ៉ាប់រង។ គោលដៅរបស់យើងគឺធ្វើឱ្យផ្ទះដែលរងការបំផ្លិចបំផ្លាញទាំងនោះអាចមានសុវត្ថិភាព  អនាម័យ និងដំណើរបានតាមធម្មតាវិញ។

**ការជំនួសៈ** លុយមានសំរាប់ម្ចាស់ផ្ទះទាំងឡាយណាដែលត្រូវជំនួសផ្ទះរបស់ពួកគេដែលរងការបំផ្លិចបំផ្លាញ ដោយគ្រោះមហន្តរាយ ហើយដែលពុំមានធានារ៉ាប់រង។ គោលដៅរបស់យើងគឺជួយម្ចាស់ផ្ទះនូវតំលៃនៃ ការជំនួសផ្ទះរបស់ពួកគេដែលត្រូវបានបំផ្លាញទៅហើយនោះ។

**ការសាងសង់ផ្ទះជាអចិន្ត្រៃយ៍/ពាក់កណ្តាលអចិន្ត្រៃយ៍ៈ** ជំនួយដោយផ្ទាល់ ឬ ថវិកាសំរាប់ការសាងសង់ផ្ទះ។ ជំនួយប្រភេទនេះ មានសំរាប់តែក្នុងតំបន់កោះ ឬទីតាំងដាច់ស្រយាល ដែលបានកំណត់ ដោយ FEMA ដែលនៅតំបន់នោះពុំមានជំនួយលើជំរកស្នាក់នៅឡើយ។

***តំរូវការដទៃទៀតៈ*** ថវិកាសំរាប់ការចំណាយចាំបាច់ និងតំរូវការធំៗ ដែលបានបណ្តាលដោយគ្រោះមហន្តរាយ ។ តំរូវការនេះ រាប់បញ្ចូលទាំងផ្នែកពេទ្យ ធ្មេញ បុណ្យសព ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ការដឹកជញ្ជូន ការផ្លាស់ប្តូទីលំនៅ និង ឃ្លាំង ហើយនិងការចំណាយដទៃទៀត ដែលអនុញ្ញាតដោយច្បាប់ ។

# សិទ្ធិពលរដ្ឋ និងជំនួយសំរាប់គ្រោះមហន្តរាយរបស់អ្នក

ច្បាប់អំពីជំនួយសង្គ្រោះបន្ទាន់ និងជំនួយសំរាប់គ្រោះមហន្តរាយ (Robert T. Stafford Disaster Relief and Emergency Assistance Act – Stafford Act) គឺជាច្បាប់ដែលអនុញ្ញាតឱ្យមាននូវជំនួយរបស់សហព័ន្ធ នៅពេលដែលប្រធានាធិបតី ប្រកាសថា រដ្ឋមួយជាតំបន់ដែលមានគ្រោះមហន្តរាយ ។ ផ្នែក 308 នៃច្បាប់ Stafford បានការពារដល់ឯកត្តបុគ្គល ទាំងឡាយពីការរើសអើងដោយឈរលើមូលដ្ឋានមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ សាសនា សញ្ជាតិ ភេទ អាយុ ឬស្ថានភាពសេដ្ឋកិច្ច នៅក្នុងកម្មវិធីជំនួយសង្គ្រោះមហន្តរាយទាំងអស់ ។ ផ្នែក 309 នៃច្បាប់ Stafford អនុវត្តតាមខទាំងឡាយដែលមិនមានការរើសអើងចំពោះគ្រប់អង្គការផ្តល់ជំនួយសង្គ្រោះឯកជន ដែលចូល រួមនៅក្នុងការកិច្ចខិតខំប្រឹងប្រែងឆ្លើយតប និងការដែលធ្វើឱ្យមានភាពប្រសើរឡើងវិញ ។

ជាងនេះទៅទៀត សិទ្ធិកម្មសិទ្ធិ VI នៃច្បាប់ស្តីអំពីសិទ្ធិពលរដ្ឋ (Civil Rights Act)ឆ្នាំ 1964 ក៏ការពារឯកត្តជន មិនឱ្យមានការ រើសអើងប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ឬដើមកំណើត នៅក្នុងកម្មវិធីដែលទទួលបាន ជំនួយហិរញ្ញវត្ថុរបស់សហព័ន្ធនោះឡើយ ។ ផ្នែក 504 នៃច្បាប់បុននីតសម្បទា (Rehabilitation Act) ឆ្នាំ 1973 គឺជា ច្បាប់សហព័ន្ធដែលការពារ ឯកត្តបុគ្គលពិការ មិនឱ្យមានការរើសអើងនៅក្នុងគ្រប់កម្មវិធីទាំងអស់ដែល ទទួលមូលនិធិពីរដ្ឋាភិបាល សហព័ន្ធ ឬដំណើរការដោយរដ្ឋាភិបាលសហព័ន្ធ ។ ផ្នែក 508 នៃច្បាប់នោះបានធ្វើ ការហាមឃាត់មិនឱ្យ មានការរើសអើងប្រឆាំងនឹងបុគ្គលទាំងឡាយណាដែលពិការ ដែលជាការគោរពចំពោះ ប្រព័ន្ធបច្ចេកវិទ្យា ដែល ដំណើរការដោយសហព័ន្ធ ។

# ដំណើរការជំនួយសំរាប់គ្រោះមហន្តរាយ

**ត្រូវប្រើពលរដ្ឋដែលស្ថិតនៅក្នុងតំបន់ទទួលរងគ្រោះមហន្តរាយដែលត្រូវបានប្រកាស ដោយប្រធានាធិបតី:**

1. **ដាក់ពាក្យតាមអ៊ីនធឺណិត ដោយចូលមើលគេហទំព័រ *www.fema.gov* ឬតាមទូរស័ព្ទ ដោយចុចទៅលេខ** 1-800-621-3362 (FEMA) (សំរាប់អ្នកថ្លង់/គ - ទូរស័ព្ទទៅលេខ 1-800-462-7585). ក្រៅពីមានប៊ិច និងក្រដាស សូមត្រៀមព័ត៌មានដូចខាងក្រោម:

- លេខសន្តិសុខសង្គម (Social Security Number) របស់អ្នក ។
- ការពិពណ៌នាអំពីការខូចខាតនានាដែលបង្កដោយគ្រោះមហន្តរាយ ។
- ព័ត៌មានពីការធានារ៉ាប់រង ។
- ការបង្ហាញផ្លូវទៅកាន់ទ្រព្យសម្បត្តិរបស់អ្នកដែលរងការខូចខាត ។
- លេខទូរស័ព្ទទំនាក់ទំនងទៅអ្នក ។

នៅពេលអ្នកដាក់ពាក្យតាមទូរស័ព្ទ ព័ត៌មានដែលអ្នកផ្ដល់ជូននឹងត្រូវរក្សាទុកនៅក្នុងកុំព្យូទ័រ ហើយសំណុំបែបបទក៏ត្រូវបានគេរៀបចំឡើង ។ នៅពេលដែលសំណុំបែបបទនៃការដាក់ពាក្យរបស់អ្នកត្រូវបានគេបំពេញ ចប់សព្វគ្រប់ហើយនោះ គេនឹងផ្ដល់អត្តលេខសម្រាប់ពាក្យស្នើសុំរបស់ FEMA មួយ ។

បើអ្នកមានសំណួរ ក្រោយពេលដែលអ្នកបានដាក់ពាក្យសុំជំនួយរួចហើយ ឬបើសិនជាព័ត៌មានដែលអ្នកបានផ្ដល់ មានការផ្លាស់ប្ដូរ សូមទូរស័ព្ទទៅកាន់ខ្សែទូរស័ព្ទជំនួយរបស់ FEMA ដែលមានលេខ 1-800-621-3362 (FEMA) (សំរាប់អ្នកថ្លង់/គ — សូមទូរស័ព្ទទៅលេខ 1-800-462-7585) ។ នៅពេលអ្នកទូរស័ព្ទទៅ សូមត្រៀមអត្តលេខនៃពាក្យស្នើសុំឱ្យបានរួចជាស្រេច ។ គេនឹងផ្ដល់អត្តលេខនេះទៅអ្នក នៅពេលអ្នកដាក់ពាក្យ ហើយក៏ផ្ញើសំបុត្រទៅអ្នក ពី IHP ផងដែរ ។

2. **តើអធិការនឹងទាក់ទងមកខ្ញុំនៅពេលណា?** បើសិនជាអ្នកមិនមានកាធានារ៉ាប់រង ឬខ្វះការធានារ៉ាប់រងមួយដែលសមស្របពេញលេញ អធិការនឹងទូរស័ព្ទទៅរៀបចំការណាត់ជួបមួយ ដើម្បីចុះទៅពិនិត្យមើលទ្រព្យសម្បត្តិរបស់អ្នក ។ ក្នុងករណីមួយចំនួន គេនឹងទាក់ទងទៅអ្នកនៅថ្ងៃដែលអ្នកមកដាក់ពាក្យ ។ ទោះជាយ៉ាងនេះក្តី ក្នុងករណីភាគច្រើន អធិការនឹងទូរស័ព្ទទៅក្នុងរយៈពេលពីរបីថ្ងៃក្រោយ ប៉ុន្តែជាធម្មតាមិនឱ្យលើសពី ១០ថ្ងៃនោះទេ ។

អធិការនឹងវាយតំលៃការខូចខាតដែលទាក់ទងនឹងគ្រោះមហន្តរាយសំរាប់ទ្រព្យសម្បត្តិអចលនទ្រព្យ និងទ្រព្យផ្ទាល់ខ្លួនរបស់អ្នក ។ ពុំមានការបង់ថ្លៃអ្វីទៅចំពោះការចុះធ្វើអធិការកិច្ចនេះទេ ។ អធិការគឺជាក្រុមហ៊ុន ម៉ៅការ មិនមែនជាបុគ្គលិករបស់ FEMA ទេ ប៉ុន្តែអធិការរបស់អ្នកក៏មានពាក់អត្តសញ្ញាណដែលមានបិទ រូបថតផងដែរ ។ អ្នក ឬបុគ្គលណាដែលមានអាយុ ១៨ឆ្នាំ ដែលរស់នៅក្នុងផ្ទះនេះ មុនពេលគ្រោះមហន្តរាយកើត ឡើង ត្រូវមានវត្តមានតាមការណាត់ជួបរបស់អ្នក ។

អធិការនឹងសុំមើលអត្តសញ្ញាណរបស់អ្នក ហើយអ្នកត្រូវតែបង្ហាញភស្តុតាងនានាដែលបញ្ជាក់ពីកម្មសិទ្ធិ (សំរាប់ម្ចាស់ផ្ទះ) និងការមកកាន់កាប់ដើម្បីបង្ហាញដល់អធិការ ។

អធិការនឹងសុំឱ្យអ្នកចុះហត្ថលេខាលើសំណុំបែបបទមួយដែលអនុញ្ញាតឱ្យ FEMA ធ្វើការបញ្ជាក់ថា ព័ត៌មានដែលអ្នកបានផ្តល់គឺពិតជាត្រឹមត្រូវ ។ **អធិការរៀបចំធ្វើរបាយការណ៍របស់អ្នក ប៉ុន្តែមិនធ្វើការសំរេចចំពោះសិទ្ធិស្របច្បាប់របស់អ្នកឡើយ ។**

3. **ក្នុងរយៈពេល ១០ថ្ងៃនៃការចុះពិនិត្យមើលរបស់អធិការ** អ្នកនឹងទទួលបានលិខិតមួយ ច្បាប់ពី IHP ធ្វើការជូនដំណឹងដល់អ្នកអំពីការសំរេចចិត្តទៅលើសំណើសុំជំនួយរបស់អ្នក ។

- **បើអ្នកមានសិទ្ធិនឹងទទួលបានជំនួយ** ក្រោយទទួលបានសំបុត្រហើយ នឹងមានមូលប្បទានប័ត្ររបស់ រតនាគារអាមេរិក/រដ្ឋ ឬនឹងមានការផ្ទេរសាច់ប្រាក់ចូលគណនីធនាគាររបស់អ្នក ។ សំបុត្រនោះ

នឹងពន្យល់អំពីអ្វីដែលថវិកានោះអាចយកទៅប្រើប្រាស់បាន ។ អ្នកគួរប្រើប្រាស់ថវិកា ដែលបានផ្តល់ជូននោះឱ្យដូចទៅនឹងអ្វីដែលបានពន្យល់នៅក្នុងសេចក្តីនៃសំបុត្រនេះ ។

- **បើសិនជាអ្នកពុំមានសិទ្ធិទទួលបានជំនួយនេះទេ** លិខិតនេះនឹងផ្តល់នូវមូលហេតុនៃការសំរេចចិត្តនោះ ។
  ក្នុងនោះផងដែរគេក៏ផ្តល់ដំណឹងជូនអ្នកពីសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ទៅនឹងសេចក្តីសម្រេចដែលមាននៅក្នុងសេចក្តីសំបុត្រនេះ ។

- **បើសិនជាណែនាំអ្នកឱ្យទៅរកជំនួយពី រដ្ឋបាលជំនួញខ្នាតតូច (Small Business Administration, SBA)** ពីកម្មវិធីជំនួយសំរាប់ គ្រោះមហន្តរាយរបស់ SBA អ្នកនឹងទទួលបានពាក្យស្នើសុំរបស់ SBA មួយច្បាប់ ។

# សិទ្ធិស្របច្បាប់ក្នុងការទទួលយកកម្មវិធី

**ដើម្បីទទួលបានថវិកា ឬជំនួយសំរាប់ តំរូវការជំរកស្នាក់នៅ ដែលជាផលបង្កដោយគ្រោះមហន្តរាយនោះ ចំណុចខាងក្រោមទាំងអស់នេះត្រូវតែពិត និងត្រឹមត្រូវ:**

- អ្នកបានរៀបចំឯកសារដើម្បីស្នើសុំផលប្រយោជន៍ពីការធានារ៉ាប់រង ហើយការខូចខាតចំពោះទ្រព្យសម្បត្តិរបស់អ្នក មិនត្រូវចេញសងដោយការធានារ៉ាប់រងរបស់អ្នក ។ អ្នកប្រហែលជាមានសិទ្ធិស្នើសុំជំនួយពី IHP ដើម្បីជួសជុលការខូចខាតដែលមានមកលើទ្រព្យសម្បត្តិរបស់អ្នក ។

- អ្នក ឬបុគ្គលណាម្នាក់ដែលរស់នៅជាមួយអ្នក គឺជាពលរដ្ឋរបស់សហរដ្ឋអាមេរិក ពលរដ្ឋមិនទាន់ចូលសញ្ជាតិ ឬជនបរទេសដែលមានលក្ខណ:គ្រប់គ្រាន់ ។

- ផ្ទះរបស់អ្នកស្ថិតនៅក្នុងតំបន់ដែលប្រធានាធិបតីប្រកាសថាជាតំបន់ទទួលរងគ្រោះមហន្តរាយ ។

- ផ្ទះនៅក្នុងតំបន់ទទួលរងគ្រោះមហន្តរាយ គឺជាកន្លែងដែលអ្នករស់នៅយូរ ក្នុងមួយ ឆ្នាំ។ ។

- អ្នកមិនអាចរស់នៅក្នុងផ្ទះរបស់អ្នកបាននោះទេនាពេលឥឡូវនេះ ហើយអ្នកមិនអាចទៅផ្ទះរបស់អ្នកបានដោយ សារតែគ្រោះហមន្តរាយ ឬផ្ទះរបស់អ្នកតម្រូវឱ្យមានការជួសជុល ដោយសារការខូចខាតដែលបណ្ដាលមកពីគ្រោះមហន្តរាយ ។

**ដើម្បីទទួលបានលុយ សំរាប់ <u>តំរូវការលើសពីជំរកស្នាក់នៅ</u> ដែលជាលទ្ធផលនៃការបង្កគ្រោះមហន្តរាយ ចំណុចខាងក្រោមទាំងអស់នេះត្រូវតែពិត និងត្រឹមត្រូវ:**

- អ្នកមានការខូចខាតស្ថិតនៅក្នុងតំបន់ ដែលប្រធានាធិបតីប្រកាសថាជាតំបន់ទទួលរងគ្រោះមហន្តរាយ ។
- អ្នកបានរៀបចំឯកសារដើម្បីស្នើសុំផលប្រយោជន៍ពីការធានារ៉ាប់រង ហើយការខូចខាតចំពោះទ្រព្យសម្បត្តិផ្ទាល់របស់អ្នក មិនត្រូវចេញសងដោយការធានារ៉ាប់រងរបស់អ្នក ។ អ្នកប្រហែលជាមានសិទ្ធិស្នើសុំជំនួយពី IHP ដើម្បីយកមកជួសជុលការខូចខាតទាំងឡាយដែលមានមកលើទ្រព្យសម្បត្តិ របស់អ្នក ។
- អ្នក ឬបុគ្គលណាម្នាក់ដែលរស់នៅជាមួយអ្នក គឺជាពលរដ្ឋរបស់សហរដ្ឋអាមេរិក ពលរដ្ឋមិនទាន់ចូលសញ្ជាតិ ឬជនបរទេសដែលមានលក្ខណៈគ្រប់គ្រាន់ ។
- អ្នកមានការចំណាយចាំបាច់ ឬតំរូវការធំៗ ដោយសារតែគ្រោះមហន្តរាយនេះ ។
- អ្នកបានទទួលជំនួយពីគ្រប់ប្រភពដទៃផ្សេងទៀត ដូចជាការប្ដឹងក្រុមហ៊ុនធានារ៉ាប់រង ឬឥណទានរបស់ SBA ។

**អ្នកប្រហែលជា<u>មិនមានសិទ្ធិទទួល</u>ថវិកា ឬជំនួយពី IHP បើសិនជា:**

- អ្នកមានកន្លែងរស់នៅដែលឥតបង់ថ្លៃឈ្នួលផ្សេងទៀត ដែលអ្នកអាចប្រើបាន (ឧទាហរណ៍ ផ្ទះជួលដែលមិនមានគេរស់នៅ) ។

- ផ្ទះដែលរងការខូចខាតនោះ គឺជាផ្ទះសំរាប់សំរាកលំហែកាយ ឬផ្ទះទីពីររបស់អ្នក។

- ការចំណាយរបស់អ្នកកើតឡើងដោយសារតែការចាកចេញពីផ្ទះរបស់អ្នកដើម្បីការពារខ្លួន ហើយអ្នកមិនអាចវិលត្រឡប់ទៅផ្ទះរបស់អ្នកវិញភ្លាមបន្ទាប់ពីមានឧប្បត្តិហេតុ។

- អ្នកបានបដិសេធជំនួយពីក្រុមហ៊ុនផ្តល់សេវាធានារ៉ាប់រងរបស់អ្នក។.

- ការខូចខាតរបស់អ្នក គឺជាការខូចខាតរបស់ក្រុមហ៊ុន (រាប់បញ្ចូលទាំងក្រុមហ៊ុនកសិដ្ឋាន តែមិនមែនជាផ្ទះកសិករ និងការងារឯកជនខ្លួនឯង) ឬក៏របស់ដែលខូចខាតទាំងនោះមិនមាននៅក្នុងកម្មវិធីនេះ។

- ផ្ទះខូចខាតដែលជាកន្លែងអ្នករស់នៅ គឺស្ថិតក្នុងតំបន់ដែលគេកំណត់ថាជាកន្លែងដែលអាចទទួលរងគ្រោះដោយសារទឹកជំនន់ ហើយសហគមន៍របស់អ្នកមិនចូលរួមនៅក្នុងកម្មវិធីធានារ៉ាប់រងសំរាប់គ្រោះទឹកជំនន់ជាតិ។ នៅក្នុងករណីនេះ ការខូចខាតផ្ទះដោយសារទឹកជំនន់នឹងមិនមានបញ្ចូលឡើយ ប៉ុន្តែអ្នកប្រហែលជាមានសិទ្ធិនឹងទទួលបានជំនួយជាថ្លៃជួល ឬការខូចខាតចំពោះសំភារៈទាំងឡាយណាដែលពុំមាននៅក្នុងការធានារ៉ាប់រងសំរាប់គ្រោះទឹកជំនន់ ដូចជាចំណាយថ្លៃអណ្តូងទឹក ប្រព័ន្ធទទួលទឹកសំអុយ ពេទ្យធ្មេញ បុណ្យសព។

# ប្រភេទនៃការខូចខាតទាំងឡាយដែលមានសិទ្ធិទទួលយកកម្មវិធី

**IHP មានតែថវិកាសំរាប់ការជួសជុល ឬការផ្លាស់ប្តូរសំភារៈទាំងឡាយណាដែលរងការខូចខាត ដោយសារតែលទ្ធផលផ្ទាល់នៃគ្រោះមហន្តរាយ ដែលពុំមាននៅក្នុងការធានារ៉ាប់រង។ ការជួសជុល ឬការសាងសង់ឡើងវិញ ប្រហែលជាមិនអាចធ្វើឱ្យផ្ទះរបស់អ្នកប្រសើរឡើង លើសពីស្ថានភាពមុនពេលមានគ្រោះមហន្តរាយនោះទេ លុះណាតែការដែលធ្វើឱ្យប្រសើរនោះ ត្រូវបានតំរូវដោយច្បាប់សាងសង់បច្ចុប្បន្ន។**

***តំរូវការផ្ទះ:*** ថវិកាសំរាប់ការជួសជុលផ្ទះរបស់អ្នក គឺមានកំរិតត្រឹមតែធ្វើឱ្យផ្ទះរបស់អ្នកមានសុវត្ថិភាព និងមានអនាម័យ ដើម្បីឱ្យអ្នកអាចរស់នៅបាននៅទីនោះ។ IHP នឹងមិនចេញថវិកាដើម្បីធ្វើឱ្យផ្ទះរបស់អ្នក

មានសភាពដូចមុនពេលមានគ្រោះមហន្តរាយនោះឡើយ។
អ្នកប្រហែលជាប្រើថវិកាដែលផ្តល់សំរាប់តំរូវការផ្ទះនេះ ដើម្បីជួសជុលៈ

- គ្រឿងផ្ទះរបស់អ្នក (គ្រឹះ ជញ្ជាំងខាងក្រៅ និងដំបូលផ្ទះ)។
- បង្អួច ទ្វារ កំរាល ជញ្ជាំង ពិដាន និង តុទូ
- ប្រព័ន្ធលូរទឹកស្អុយ
- អណ្តូង ឬប្រព័ន្ធទឹកផ្សេងទៀត
- ប្រព័ន្ធកំដៅ ខ្យល់ចេញចូល និងម៉ាស៊ីនត្រជាក់
- ទឹក ភ្លើង (ប្រព័ន្ធភ្លើង ទឹក និងហ្គាស)
- ច្រកចូល និងចេញពីផ្ទះរបស់អ្នក រាប់បញ្ចូលទាំងផ្លូវចេញចូលផ្ទាល់ខ្លួន។
- ការបិទច្រក ការឈូសឆាយឱ្យរាបស្មើ និងការបោះយុថ្កាចងផ្ទះចល័ត និងការត ឬតំឡើង បណ្តាញលូទឹកស្អុយ ទឹក ភ្លើង ប្រេងឥន្ទៈ និងធុងសាំង។

**តំរូវការក្រៅពីផ្ទះៈ** ថវិកាសំរាប់ការជួសជុលទ្រព្យសម្បត្តិផ្ទាល់ខ្លួនដែលខូចខាត ឬសំរាប់ការបង់ថ្លៃចំណាយចាំបាច់ដែលទាក់ទងនឹងគ្រោះមហន្តរាយ ហើយនិងតំរូវការធំៗផ្សេងទៀត ត្រូវបានគេកំរិតសំរាប់តែសំភារៈ ឬសេវាទាំងឡាយណាដែលអាចជួយទប់ស្កាត់ ឬជំនះលើការលំបាក របួសស្នាម ឬលក្ខខណ្ឌមិនអនុគ្រោះ ដែលពាក់ព័ន្ធនឹងគ្រោះមហន្តរាយ។ IHP នឹងមិនចេញថ្លៃដែលធ្វើឱ្យទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់អ្នកវិលត្រឡប់មករកស្ថានភាពមុនពេលមានគ្រោះមហន្តរាយនោះឡើយ។
អ្នកអាចប្រើថវិការបស់អ្នកដែលគេ ផ្តល់ឱ្យសំរាប់តំរូវការក្រៅពីផ្ទះ ដើម្បីយកទៅជួសជុល ឬបង់ៈ

- ថ្លៃគ្រូពេទ្យ និងធ្មេញដែលពាក់ព័ន្ធនឹងគ្រោះមហន្តរាយ។
- ថ្លៃធ្វើបុណ្យសព និងកប់ខ្មោច ដែលទាក់ទងនឹងគ្រោះមហន្តរាយ។

- សំលៀកបំពាក់ របស់របរប្រើប្រាស់ក្នុងផ្ទះ (គ្រឿងសង្ហារឹមសំរាប់បន្ទប់ គ្រឿងអគ្គិសនី) ឧបករណ៍ផ្សេងៗ (សំលៀកបំពាក់ និងសំភារៈសំរាប់ការពារ ឬសំរាប់ជំនាញអ្វីមួយ) ដែលចាំបាច់សំរាប់ការងាររបស់អ្នក សំភារៈសិក្សាចាំបាច់ (កុំព្យូទ័រ សៀវភៅ និងសំភារៈសិក្សារផ្សេងទៀត) ។

- ប្រេងឥន្ទៈសំរាប់ផ្គត់ផ្គង់ប្រភពកំដៅចាំបាច់ (ប្រេងសំរាប់ប្រព័ន្ធកំដៅ ឧស្ម័ន អុស) ។

- សំភារៈសំរាប់សំអាតដែលមានការណែនាំឱ្យប្រើសំរាប់គ្រោះមហន្តរាយ (ម៉ាស៊ីនបូមធូលីសើម/ស្ងួត ម៉ាស៊ីនធ្វើឱ្យខ្យល់បរិសុទ្ធ និងឧបករណ៍បំបាត់សំណើម) ។

- យានយន្តដែលខូចដោយសារគ្រោះមហន្តរាយ ។

- ការចំណាយសំរាប់ការរើផ្ទះ និងឃ្លាំងដែលទាក់ទងនឹងគ្រោះមហន្តរាយ (ទ្រព្យសម្បត្តិប្រើសំរាប់រើ និងសំរាប់រក្សាទុក ដើម្បីជៀសវាងការខូចខាតដោយគ្រោះមហន្តរាយបន្ថែមទៀត នៅពេលមានការជួសជុលទាក់ទងនឹងគ្រោះមហន្តរាយ ត្រូវបានគេធ្វើឡើង ដល់ផ្ទះនេះ) ។

- ការចំណាយចាំបាច់ដទៃទៀត ឬតំរូវការធំៗ ដូចដែលបានកំណត់ដោយ FEMA ។

# ព័ត៌មានសំខាន់អំពីជំនួយសំរាប់គ្រោះមហន្តរាយ

លុយដែលបានទទួលពី IHP សំរាប់ផ្ទះ និងសំរាប់តំរូវការផ្សេងទៀតក្រៅពីផ្ទះ ត្រូវតែយកទៅប្រើប្រាស់សំរាប់ការចំណាយទាំងឡាយណាដែលគេអនុញ្ញាត ដូចដែលបានកំណត់ដោយ FEMA:

- **បើសិនជាអ្នកមិនបានប្រើប្រាស់ថវិកាតាមការពន្យល់ប្រាប់ដោយ FEMA នោះទេ អ្នកនឹងមិនមានសិទ្ធិសុំជំនួយបន្ថែមឡើយ ហើយអ្នកប្រហែលជាត្រូវប្រគល់ថវិកានោះមកវិញ ។**

- ជាធម្មតាត្រូវបានគេកំរិតត្រឹម ១៨ខែ គិតចាប់ពី កាលបរិច្ឆេទដែលប្រធានាធិបតី ធ្វើការប្រកាសអំពីគ្រោះមហន្តរាយនេះ ។

- មិនចាំបាច់សងវិញឡើយ ។

- ឥតមានជាប់ពន្ធ ។

- មិនត្រូវបានគេចាត់ទុកថាជាប្រាក់ចំណូល ឬធនធានមួយក្នុងការកំណត់អំពីភាពមានសិទ្ធិស្របច្បាប់ក្នុងការទទួលយកនូវសេវាសុខមាលភាព ជំនួយលើប្រាក់ចំណូល ឬកម្មវិធីផ្តល់អត្ថប្រយោជន៍ដែលមានការធ្វើតេស្តន៍អំពីប្រាក់ចំណូល ដែលកម្មវិធីទាំងនេះទទួលមូលនិធិពីរដ្ឋាភិបាលសហព័ន្ធ ។

- រួចផុតពីបណ្តឹងរឹបអូសពីតតិយជន ការរឹបអូស បន្ទុកលើអចលនទ្រព្យ ពន្ធ ការប្រតិបត្តិការសន្យា អំណូសឃាត់ ការដោះលែង ឬការឈប់ទាមទារសិទ្ធិ ។

- មិនអាចចាត់ចែងឡើងវិញ ឬផ្ទេរទៅបុគ្គលផ្សេងឡើយ ។

- ***អ្នកត្រូវតែរក្សាទុកវិក្កយប័ត្រទាំងអស់រយៈពេល៣ឆ្នាំ ដើម្បីបង្ហាញថាថវិកានោះត្រូវបានប្រើប្រាស់ទៅតាមសេចក្តីត្រូវការរបស់អ្នកដែលទាក់ទងនឹងគ្រោះមហន្តរាយ ។***

| |
|---|
| មុនពេលអ្នកចាប់ផ្តើមធ្វើការជួសជុលណាមួយ សូមសាកសួរផ្នែកសាងសង់ក្នុងតំបន់របស់អ្នក ដើម្បីស្វែងយល់ថាតើការអនុញ្ញាត ឬការធ្វើអធិការកិច្ចអ្វីខ្លះដែលគេត្រូវឱ្យ ។ |

# បើសិនជាអ្នកមានសិទ្ធិទទួលយកជំនួយ

បើសិនជាការដាក់ពាក្យរបស់អ្នកដើម្បីសុំជំនួយក្រោមកម្មវិធី IHP បានឆ្លើយតបតាមលក្ខខណ្ឌដែលគេតំរូវ ហើយទទួលបានការយល់ព្រមហើយនោះ ថវិកា ឬជំនួយដែលអ្នកនឹងទទួលត្រូវតែប្រើទៅតាមការពិពណ៌នាដូចខាងក្រោម ។ ថវិកាដែលបានមកពីកម្មវិធីនេះ **មិនអាច**យកទៅប្រើដើម្បីបង់ថ្លៃស្នាក់នៅជាមួយ គ្រួសារ ឬមិត្តភ័ក្រឡើយ ។ ខាងក្រោមនេះ គឺជាការពន្យល់អំពីជំពូកនានាដែលពាក់ព័ន្ធ ។

**ធ្មេញ:** ថវិកាដែលត្រូវយកទៅទូទាត់ថ្លៃព្យាបាលធ្មេញ ដោយការរងរបួសធ្មេញក្នុងពេលមានគ្រោះមហន្តរាយ ។

**បុណ្យសព:** ថវិកាដែលត្រូវយកទៅដោះស្រាយថ្លៃសេវាបុណ្យសព ការបញ្ចុះសព ឬការបូជាសព និងការចំណាយលើពិធីបុណ្យសពផ្សេងៗទៀត ដែលទាក់ទងនឹងមរណៈភាព ដែលបង្កឡើងដោយគ្រោះមហន្តរាយ ។

**ការជួសជុលផ្ទះ:** ថវិកាមានសំរាប់ម្ចាស់ផ្ទះទាំងឡាយណា ដែលត្រូវការយកទៅទូទាត់ថ្លៃកំលាំងពលកម្ម និង សំភារៈ ដែលត្រូវការយកមកជួសជុលផ្ទះឱ្យមានសុវត្ថិភាព អនាម័យ និង/ឬដំណើរការបាន ។

**ជំនួយផ្នែកផ្ទះ:** ជួយដោះស្រាយថ្លៃតំរូវការផ្ទះ ដែលទាក់ទងនឹងគ្រោះមហន្តរាយ ។

**ពេទ្យ:** ថវិកាសំរាប់ដោះស្រាយថ្លៃការព្យាបាល ឬការទិញសំភារៈពេទ្យ ដែលគេតំរូវឱ្យ ពីព្រោះតែរបួសស្នាមខាងរាងកាយដែលអ្នកបានទទួល ដោយសារលទ្ធផលនៃគ្រោះមហន្តរាយ ។

**ការរុះរើ និងការរក្សាទុក:** ថវិកាសំរាប់ការទូទាត់ថ្លៃរុះរើ និងរក្សាទុកទ្រព្យសម្បត្តិផ្ទាល់ខ្លួនឱ្យផុតពីកន្លែង ដែលមានរងគ្រោះមហន្តរាយ ដើម្បីជៀសវាងការខូចខាតបន្ថែមទៀតដែលទាក់ទងនឹងមហន្តរាយ ។

**ផ្សេងៗ:** ថវិកាសំរាប់ទូទាត់ថ្លៃតំរូវការទាក់ទងនឹងគ្រោះមហន្តរាយពិសេសផ្សេងៗទៀត ដែលបានយល់ព្រម សំរាប់គ្រោះមហន្តរាយ ។

**ផ្ទះអចិន្ត្រៃយ៍ /ពាក់កណ្ដាលអចិន្ត្រៃយ៍:** ដោយសារមានកង្វះខាតខាងធនធានសំរាប់ជួល ភាពមិនអាចធ្វើបាន នៃជំនួយសំរាប់ការជួសជុលផ្ទះ និងផ្ទះជំនួស និងកង្វះខាតខាងអ្នកម៉ៅការសំណង់នៅក្នុងតំបន់របស់អ្នក FEMA នឹងឱ្យគេសារសង់ផ្ទះរបស់អ្នកឡើងវិញ ។

**ទ្រព្យសម្បត្តិផ្ទាល់ខ្លួន:** ថវិកាសំរាប់ការទូទាត់ថ្លៃការជួសជុល និង/ឬជំនួសរបស់របរដែលរងខូចខាតដោយសារគ្រោះមហន្តរាយ ដូចជាគ្រឿងសង្ហារឹម គ្រែ សំភារៈអគ្គិសនី និងសំលៀកបំពាក់ ។

**ជំនួយសំរាប់ការជួល:** ថវិកាសំរាប់ការទូទាត់ថ្លៃជួលកន្លែងមួយទៀតដើម្បីរស់នៅ ។ ចំពោះម្ចាស់ផ្ទះ ថវិកានេះ អាចផ្ដល់ជូនបន្ថែមពីលើការជួសជុលផ្ទះ បើសិនជាត្រូវការ ។

**ផ្ទះជំនួស:** ថវិកាសំរាប់ជួយថ្លៃជំនួសផ្ទះរបស់អ្នក ដែលមានរហូតដល់ទៅចំនួនមួយដែលអនុញ្ញាតដោយច្បាប់ ពីព្រោះផ្ទះរបស់អ្នកមិនមានសុវត្ថិភាព អនាម័យ និង/ឬមិនដំណើរការ ។

**កន្លែងស្នាក់នៅបណ្ដោះអាសន្ន:** ថវិកាសំរាប់ការទូទាត់ថ្លៃចំណាយការស្នាក់នៅបណ្ដោះអាសន្ន (សណ្ឋាគារ ឬផ្ទះសំណាក់) ដែលទាក់ទងនឹងគ្រោះមហន្តរាយ ។

**មធ្យោបាយដឹកជញ្ជូន:** ថវិកាសំរាប់ទូទាត់ថ្លៃជួសជុល និង/ឬជំនួសយានយន្តរបស់អ្នកដែលមិនអាចប្រើបានដោយសារការខូចខាតដែលទាក់ទងនឹងគ្រោះមហន្តរាយ ។

## ព័ត៌មានអំពីការធានារ៉ាប់រង និងជំនួយសំរាប់គ្រោះមហន្តរាយ

**បើសិនជាអ្នកមិនទាន់បានទាក់ទងជាមួយភ្នាក់ងារធានារ៉ាប់រងរបស់អ្នក ដើម្បីរៀបចំឯកសារទាមទារសំណងនៅឡើយទេ សូមប្រញាប់ធ្វើរឿងនេះឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ។** ការខកខានមិនបានរៀបចំឯកសារទាមទារសំណងពីក្រុមហ៊ុនធានារ៉ាប់រងរបស់អ្នក អាចប៉ះពាល់ដល់សិទ្ធិរបស់អ្នកក្នុងការទទួលជំនួយពី IHP ។ បន្ទាប់ពីបានរៀបចំឯកសារទាមទាររួចហើយ បើសិនជាមានស្ថានភាពដូចខាងក្រោមកើតឡើង សូមទូរស័ព្ទមក ខ្សែទូរស័ព្ទសំរាប់ជំនួយគ្រោះមហន្តរាយ FEMA ដែលមានលេខ 1-800-621-3362 (FEMA) ដើម្បីសាកសួរព័ត៌មានបន្ថែម ។

- **ការដោះស្រាយពីក្រុមហ៊ុនធានារ៉ាប់រងរបស់អ្នកត្រូវពន្យារពេល។** បើសិនជាការសំរេចចិត្តចំពោះការដោះស្រាយពីក្រុមហ៊ុនធានារ៉ាប់រងរបស់អ្នក ត្រូវបានគេពន្យារពេលលើសពី ៣០ថ្ងៃ **គិតចាប់ពីពេលដែលអ្នកបានរៀបចំឯកសារធ្វើការទាមទារមក** អ្នកត្រូវសរសេរលិខិតមួយច្បាប់ទៅ FEMA ធ្វើការពន្យល់អំពីកាលៈទេសៈនេះ។ អ្នកគួរតែភ្ជាប់សំណុំឯកសារពីក្រុមហ៊ុនធានារ៉ាប់រងដែលបញ្ជាក់ថាអ្នកបានរៀបចំឯកសារទាមទារមែន។ បើសិនជាអ្នកបានធ្វើការទាមទារតាមទូរស័ព្ទ អ្នកគួរតែភ្ជាប់មកជាមួយនូវលេខទាមទារ កាលបរិច្ឆេទដែលអ្នកបានដាក់ពាក្យ រយៈពេលដែលគេប៉ាន់ស្មានថានឹងត្រូវប្រើដើម្បីនឹងទទួលបានការដោះស្រាយរបស់អ្នក។ ជំនួយណាមួយដែល FEMA ផ្តល់ជូនអ្នក នឹងចាត់ទុកថាជាការវិវឌ្ឍន៍ទៅមុខ ហើយអ្នកត្រូវតែសងទៅ FEMA វិញ ខណៈដែលអ្នកបានទទួលការដោះស្រាយពីក្រុមហ៊ុនធានារ៉ាប់រង។

- **ការដោះស្រាយពីក្រុមហ៊ុនធានារ៉ាប់រងមិនគ្រប់គ្រាន់ល្មមនឹងឆ្លើយតបតាមតំរូវការដែលទាក់ទងនឹងគ្រោះមហន្តរាយរបស់អ្នកឡើយ។** បើសិនជាអ្នកបានទទួលការដោះស្រាយសំណងជាអតិបរិមាពីក្រុមហ៊ុនធានារ៉ាប់រង ហើយនៅតែមិនអាចឆ្លើយតបនឹងតំរូវការដែលទាក់ទងនឹងគ្រោះមហន្តរាយ អ្នកត្រូវសរសេរលិខិតមួយច្បាប់ទៅ FEMA ធ្វើការបង្ហាញអំពីតំរូវការដែលទាក់ទងនឹងគ្រោះមហន្តរាយដែលមិនអាចដោះស្រាយបាន។ អ្នកក៏នឹងត្រូវផ្ញើនូវសំណុំឯកសារបានមកពីក្រុមហ៊ុនធានារ៉ាប់រង ដើម្បីគេយកមកពិនិត្យមើល។

- **អ្នកបានប្រើប្រាស់អស់នូវ ការចំណាយសំរាប់ការរស់នៅបន្ថែម** (Additional Living Expenses - ALE) **ដែលបានផ្តល់ដោយ ក្រុមហ៊ុនធានារ៉ាប់រងរបស់អ្នក។**
បើសិនជាអ្នកបានទទួលការទូទាត់សំណងជាអតិបរមាពីក្រុមហ៊ុន ធានារ៉ាប់រងរបស់អ្នក ចំពោះការចំណាយសំរាប់ការរស់នៅបន្ថែម (ប្រើប្រាស់អស់) (Additional Living Expenses - Loss of Use)ហើយនៅតែ ត្រូវការជំនួយខាងតំរូវការផ្ទះស្នាក់ នៅជាបណ្តោះអាសន្ន ដែលទាក់ទងនឹងគ្រោះមហន្តរាយ សូមសរ សេរសំបុត្រទៅ FEMA ដោយ ធ្វើការបង្ហាញពីមូលហេតុដែលអ្នកនៅតែបន្តត្រូវការផ្ទះស្នាក់នៅ ជាបណ្តោះអាសន្នទៀត។ អ្នកក៏នឹងត្រូវផ្តល់សំណុំឯកសារមកបញ្ជាក់ពីប្រាស់អស់នូវចំណែកផ្ទះនៃ ALE ពីក្រុមហ៊ុនធានា រ៉ាប់រងរបស់អ្នក ហើយនិងផែនការស្នាក់នៅជាអចិន្ត្រៃយ៍។

---

- **អ្នកមិនអាចរកកន្លែងសំរាប់ជួលបាននៅក្នុងតំបន់របស់អ្នក ។** ខ្សែទូរស័ព្ទរបស់ FEMA មានបញ្ជី កន្លែងសំរាប់ជួលនៅក្នុងតំបន់ដែលមានគ្រោះមហន្តរាយ ។ បើសិនជាកន្លែងសំរាប់ជួលមិនមាននៅក្នុងក្រុងរបស់អ្នកទេ ភ្នាក់ងារបំរើសេវាទូរស័ព្ទ អាចផ្ដល់អ្នកនូវកន្លែងសំរាប់ជួលដែលនៅជិតក្រុងរបស់អ្នក ។

**អ្នកមានពេលរហូតដល់ទៅដប់ពីរ (១២) ខែ គិតចាប់ពីកាលបរិច្ឆេទដែលអ្នកបាចុះឈ្មោះជាមួយ FEMA ដើម្បីផ្ញើព័ត៌មានអំពីការធានារ៉ាប់រងរបស់អ្នក មកឱ្យគេពិនិត្យមើល ។ តាមច្បាប់ IHP មិនអាចផ្ដល់ថវិកាទៅឱ្យឯកត្តជន ឬគេហដ្ឋាន សំរាប់ការខូចខាត ដែលមានធានារ៉ាប់រងរួចហើយឡើយ ។**

# ខ្ញុំចង់ឱ្យគេសើរើករណីរបស់ខ្ញុំឡើងវិញម្ដងទៀត (បណ្ដឹងឧទ្ធរណ៍)

**អ្នកអាចប្ដឹងឧទ្ធរណ៍នូវការសំរេចណាមួយក៏បាន ។** បណ្ដឹងឧទ្ធរណ៍ អាចទាក់ទងនឹងសិទ្ធិរបស់អ្នក ចំនួន ឬប្រភេទជំនួយដែលបានផ្ដល់ឱ្យអ្នក ការដាក់ពាក្យយឺត សំណើសុំយកថវិកាវិញ ឬសំណួរផ្សេងទៀតទាក់ទង នឹងការបន្តទទួលជំនួយ ។ នៅពេលអ្នកប្ដឹងឧទ្ធរណ៍ពីការសំរេចណាមួយ សូមអានព័ត៌មានឱ្យបានច្បាស់នៅ ក្នុងសៀវភៅមគ្គុទេសក៏នេះ អំពីការមានលក្ខណៈពេញលេញនឹងអាចទទួលយកនូវជំនួយ ឬអានលិខិតដែលគេបានផ្ញើទៅអ្នក អំពីសិទ្ធិរបស់អ្នកក្នុងការទទួលជំនួយ ។ សៀវភៅមគ្គុទេសក៏នេះ គួរតែឆ្លើយ នូវសំណួរភាគ ច្រើនរបស់អ្នក អំពីការចំណាយទាំងឡាយដែលមាននៅក្នុងកម្មវិធីនេះ ។

បន្ទាប់ពីអ្នកបានអានសៀវភៅមគ្គុទេសក៏នេះហើយ បើសិនជាអ្នកនៅតែមិនយល់ស្របជាមួយនឹងការសំរេច អំពីការដាក់ពាក្យរបស់អ្នក ឬជំនួយដែលបានទទួល **សូមអនុវត្តតាមជំហានដូចខាងក្រោមដើម្បីប្ដឹងឧទ្ធរណ៍ទៅនឹងការសំរេចនោះ:**

**ជំហានក្នុងការរៀបចំឯកសារប្ដឹងឧទ្ធរណ៍:**

1. ចូពន្យល់ជាលាយលក្ខណ៍អក្សរពីមូលហេតុដែលអ្នកគិតថាការសំរេចចំពោះចំនួន និងប្រភេទនៃជំនួយដែលអ្នកបានទទួលគឺមិនត្រឹមត្រូវ ។

- **នៅពេលផ្ញើលិខិតរបស់អ្នក** សូមសរសេរឈ្មោះពេញ  កាលបរិច្ឆេទ  ទីកន្លែងកំណើត  និងអាសយដ្ឋាន។ ជាងនេះទៅទៀត  លិខិតរបស់អ្នកត្រូវតែយកទៅឱ្យគេបញ្ជាក់នៅមន្ទីរសារការី  ភ្ជាប់នូវអត្តសញ្ញាណប័ណ្ណដែលចេញដោយរដ្ឋ មួយច្បាប់ ឬបន្ថែមការអះអាងដូចតទៅ " ខ្ញុំបាទ/នាងខ្ញុំ សូមប្រកាសអះអាងថា ព័ត៌មានខាងលើគឺពិតជាត្រឹមត្រូវ។ បើសិនជាមានចំណុចណាមួយប្រាសចាកពីការពិត ខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវចំពោះមុខច្បាប់។" អ្នកត្រូវតែចុះហត្ថលេខាលើលិខិតនោះ។

- **បើសិនជាអ្នកណាម្នាក់ មិនមែនជារូបអ្នក ឬបេក្ខជនរួមគ្នា សរសេរលិខិតនេះ** នោះត្រូវតែមានការអះអាង ដោយនិយាយថា បុគ្គលនោះអាចតំណាងអ្នកបាន។

2. សូមដាក់លេខពាក្យស្នើសុំរបស់ FEMA និងលេខគ្រោះមហន្តរាយ (ដូចមានបង្ហាញនៅផ្នែកខាងលើនៃលិខិតសំរេច របស់អ្នក) នៅក្នុងលិខិតបណ្តឹងឧទ្ធរណ៍របស់អ្នក។

3. សូមផ្ញើលិខិតបណ្តឹងឧទ្ធរណ៍របស់អ្នកទៅកាន់អាសយដ្ឋានៈ

FEMA
National Processing Service Center
P.O. Box 10055
Hyattsville, MD  20782-7055

4. អ្នកអាចផ្ញើទូរសារនូវលិខិតបណ្តឹងឧទ្ធរណ៍របស់អ្នកទៅកាន់លេខៈ

(800) 827-8112
**Attention: FEMA**

**សំខាន់ៈ** ដើម្បីឱ្យ IHP ធ្វើការពិចារណាលើលិខិតបណ្តឹងឧទ្ធរណ៍របស់អ្នក វាត្រូវតែមានបោះត្រាក្នុងរយៈពេល ៦០ថ្ងៃ នៃកាលបរិច្ឆេទនៅលើលិខិតសំរេច របស់ឯកត្តជន ឬគេហដ្ឋាន។ សូមកុំភ្លេចចុះកាលបរិច្ឆេទនៅលើលិខិតរបស់អ្នក។

### ការស្នើសុំឯកសាររបស់អ្នក:

បើសិនជាអ្នកត្រូវការព័ត៌មានអំពីករណីរបស់អ្នក  អ្នក ឬបេក្ខជនរួមគ្នា នៅលើពាក្យស្នើសុំរបស់អ្នក អាចស្នើសុំព័ត៌មាននៅក្នុងឯកសាររបស់អ្នកមួយច្បាប់ ដោយសរសេរលិខិតទៅកាន់:

**FEMA – Records Management**
**National Processing Service Center**
**P.O. Box 10055**
**Hyattsville, MD  20782-7055**

ដើម្បីជួយរក្សាការសំងាត់នូវព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក  នៅពេលណាដែលអ្នកសរសេរលិខិតបណ្ដឹងឧទ្ធរណ៍ ឬលិខិតស្នើសុំ ទៅកាន់ FEMA អ្នកគួរតែដាក់ឈ្មោះពេញ  កាលបរិច្ឆេទ  ទីកន្លែងកំណើត  អាសយដ្ឋានកន្លែងរស់នៅដែលទទួលរងគ្រោះមហន្តរាយ លេខពាក្យស្នើសុំ  និងលេខគ្រោះមហន្តរាយ ។ ក្រៅពីនេះ លិខិតរបស់អ្នកត្រូវតែយកទៅឱ្យគេបញ្ជាក់នៅមន្ទីរសារការី  ភ្ជាប់នូវអត្តសញ្ញាណប័ណ្ណដែលចេញដោយរដ្ឋមួយច្បាប់ ឬបន្ថែមការអះអាងដូចតទៅ " ខ្ញុំបាទ/នាងខ្ញុំ សូមប្រកាសអះអាងថា ព័ត៌មានខាងលើគឺពិតជាត្រឹមត្រូវ ។ បើសិនជាមានចំណុចណាមួយប្រាសចាកពីការពិត ខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវចំពោះមុខច្បាប់ ។" អ្នកត្រូវតែចុះហត្ថលេខាលើលិខិតនោះ ។

បើសិនជាអ្នកណាម្នាក់ មិនមែនជារូបអ្នក ឬបេក្ខជនរួមគ្នាផ្ញើលិខិតឧទ្ធរណ៍របស់អ្នក ឬស្នើសុំឯកសាររបស់អ្នកមួយច្បាប់  នោះការស្នើសុំនោះក៏ត្រូវតែមានការអះអាងបញ្ជាក់ពីអ្នកថាផ្ដល់ការអនុញ្ញាតឱ្យបុគ្គលនោះស្នើសុំព័ត៌មាននេះដែរ ។ ។

## ការកសាង និងការជួសជុលឡើងវិញ ~ វិធានការនានាក្នុងការបន្ធូរបន្ថយ

***វិធានការនានាក្នុងការបន្ធូរបន្ថយ*** គឺជាការធ្វើឱ្យមានភាពប្រសើរឡើង ដែលអាចកាត់បន្ថយហានិភ័យនៃការខូចខាតនៅពេលមានហេតុការណ៍កើតឡើងនៅពេលអនាគត ។ បន្ទាប់ពីមានគ្រោះមហន្តរាយដ៏ធ្ងន់ធ្ងរ

មួយ  អ្នកនឹងធ្វើការសំរេចចិត្តជាច្រើន ខណៈពេលដែលអ្នកកសាង ឬជួសជុលទ្រព្យសម្បត្តិដែលបានខូចខាត។ ការសំរេចចិត្តខ្លះ អាចជួយការពារទប់ស្កាត់កុំឱ្យទ្រព្យសម្បត្តិរបស់អ្នកមានការខូចខាតទៀត នៅពេលមានគ្រោះមហន្តរាយណាមួយផ្សេងទៀតកើតឡើង។ ឧទាហរណ៍ បើសិនជា គ្រឿងអគ្គីសនី ឬសេវាសាធារណៈសំខាន់ៗ ត្រូវបានលើកឱ្យផុតពីដីនោះ  ភវនីយភាពនៃការទទួលការខូចខាតពីគ្រោះទឹកជំនន់ក៏ ត្រូវបានគេកាត់បន្ថយផងដែរ។

ទីប្រឹក្សាខាងផ្នែកបន្ធូរបន្ថយរបស់ FEMA នៅក្នុងមជ្ឈមណ្ឌលស្តារគ្រោះមហន្តរាយ នៅក្នុងតំបន់របស់អ្នក អាចជួយផ្តល់ព័ត៌មានបន្ថែមទៀត អំពីការកាត់បន្ថយការខូចខាតនៅពេលអនាគត តាមរយៈការបន្ធូរបន្ថយ។ ខាងក្រោម គឺជាឧទាហរណ៍មួយចំនួននៃវិធានការបន្ធូរបន្ថយ។

- លើកឱ្យខ្ពស់ ឬប្តូរទីតាំងសំភារៈបញ្ជាគ្រឿងអគ្គីសនី
- លើកឱ្យខ្ពស់ ឬប្តូរទីតាំងម៉ាស៊ីនបោកខោអាវ និងម៉ាស៊ីនសម្ងួត
- បោះយុថ្កាចងធុងផ្ទុកប្រេងឥន្ធនៈ
- ពង្រាប និងបោះយុថ្កាចងផ្ទះចល័ត
- លើកឱ្យខ្ពស់   ប្តូរទីតាំង  ឬចងម៉ាស៊ីនកំដៅទឹក
- ប្តូរទីតាំង ប្រព័ន្ធម៉ាស៊ីនកំដៅ



*ការលើក ម៉ាស៊ីនកំដៅទឹកក្តៅ ចង្ក្រាន  ម៉ាស៊ីនបោកខោអាវ និងម៉ាស៊ីនសម្ងួតឱ្យបានខ្ពស់*

សំរាប់ព័តិមានបន្ថែម អំពីគម្រោងនានាក្នុងការបន្ធូរបន្ថយ ដូចដែលមានបង្ហាញនៅលើទំព័រនេះ សូមទូរស័ព្ទ ឬទៅជួបមន្ត្រីរៀបចំការគ្រប់គ្រងភាពអាសន្នប្រចាំតំបន់របស់អ្នក មន្ត្រីទទួលបន្ទុកការបន្ធូរបន្ថយការគ្រោះថ្នាក់របស់រដ្ឋ ឬបុគ្គលិករបស់ FEMA ដែលនៅតាមមជ្ឈមណ្ឌលស្តារគ្រោះមហន្តរាយ ។ ព័តិមានស្តីពីការបន្ធូរបន្ថយ ក៏មានចុះផ្សាយនៅលើគេហទំព័រ [www.fema.gov](www.fema.gov) ផងដែរ ។

ដើម្បីបញ្ជាទិញ ឯកសារបោះពុម្ពផ្សាយអំពីគម្រោងការបន្ធូរបន្ថយនានា សូមទូរស័ព្ទមកកាន់ ផ្នែកបោះពុម្ពផ្សាយរបស់ FEMA តាមលេខទូរស័ព្ទ 1-800-480-2520 ។

# ព័ត៌មានអំពីព័ត៌មានបន្ថែមទាក់ទងនឹងកម្មវិធីជំនួយសំរាប់គ្រោះមហន្តរាយ

ផ្នែកនេះមានការរៀបរាប់ជាទូទៅអំពីប្រភេទនានានៃជំនួយសំរាប់គ្រោះមហន្តរាយ ដែលមានក្នុងពេលដែលមានគ្រោះមហន្តរាយដ៏ធ្ងន់ធ្ងរមួយត្រូវបានប្រកាសដោយប្រធានាធិបតី ។ ក្នុងកំឡុងពេលមានគ្រោះមហន្តរាយធ្ងន់ធ្ងរកើតឡើង បើសិនជាអ្នកមានអារម្មណ៍ថាអ្នកមានតំរូវការផ្សេងៗទាក់ទងនឹងគ្រោះមហន្តរាយ ដែលអាចដោះស្រាយបានដោយ ទីភ្នាក់ងារ ឬសេវាណាមួយដូចដែលមានរាយនៅក្នុងផ្នែកនេះ អ្នកគួរតែធ្វើការទាក់ទងទៅ ខ្សែទូរស័ព្ទជំនួយសំរាប់គ្រោះមហន្តរាយរបស FEMA ដែលមានលេខ 1-800-621-3362 (FEMA) (សំរាប់អ្នកថ្លង់/គ: ទូរស័ព្ទទៅលេខ 1-800-462-7585) សំរាប់ព័តិមានបន្ថែម ។

**សេវាសំរាប់មនុស្សចាស់:** សេវានេះ ផ្តល់ជូនដើម្បីបង្គ្រប់សេចក្តីត្រូវការរបស់មនុស្សចាស់ ដែលទទួលរងគ្រោះដោយផ្ទាល់ ពីគ្រោះមហន្តរាយដែលបានប្រកាស (មធ្យោបាយដឹកជញ្ជូន ពេលបាយ ការមើលថែរក្សានៅតាមផ្ទះ ។ល។) ។

**ជំនួយផ្នែកកសិកម្ម:** ការអភិវឌ្ឍន៍ជនបទរបស់ USDA(USDA Rural Development) ប្រហែលជាផ្តល់ឥណទានបន្ទាន់ដល់កសិករ និងម្ចាស់កសិដ្ឋានចិញ្ចឹមសត្វ (ម្ចាស់ ឬអ្នកជួល) ដែលកំពុងដំណើរការ និងគ្រប់

គ្រងកសិដ្ឋាន ឬកសិដ្ឋានចិញ្ចឹម សត្វ នៅពេលដែលមានគ្រោះមហន្តរាយ ។ ឥណទានទាំងនេះ គឺមានកំរិតត្រឹម ចំនួនដែលចាំបាច់សំរាប់ការ ប៉ះប៉ូវដល់ការខូចខាតទ្រព្យសម្បត្តិសំខាន់របស់អ្នក និង/ឬសមត្ថភាពផលិត កម្ម ។ កសិករ និងម្ចាស់កសិដ្ឋាន ក៏អាចដាក់ពាក្យសុំជំនួយរួមគ្នា សំរាប់កម្មវិធីអភិរក្សបន្ទាន់ ដូចជាការ ប្រមូលយកកំទេចកំទីចេញពីដីដំណាំ / ដីវាលស្មៅ ការជួសជុលដល់ហេដ្ឋារចនាសម្ព័ន្ធអភិរក្សដី /ទឹក និងការធ្វើរបងជាអចិន្ត្រៃយ៍ ។ ព័ត៌មាន បន្ថែម មាននៅទីភ្នាក់ងារសេវាកម្មកសិករ (USDA Farm Service Agency - FSA) ។

**ជំនួយពីស្ថាប័នហិរញ្ញវត្ថុ:** ធានាគារទាំងឡាយដែលជាសមាជិករបស់ ក្រុមហ៊ុនសាជីវកម្ម ធានារ៉ាប់រងប្រាក់បញ្ញើសហព័ន្ធ (Federal Deposit Insurance Corporation - FDIC), ប្រព័ន្ធប្រាក់បម្រុងសហព័ន្ធ (Federal Reserve System - FRS), ឬ ក្រុមប្រឹក្សាធនាគារប្រាក់កម្ចីសំរាប់គេហដ្ឋានរបស់សហព័ន្ធ (Federal Home Loan Bank Board - FHLBB) អាចអនុញ្ញាតឱ្យមានការដកប្រាក់មុនកាលកំណត់ ដោយពុំមានការផាកពិន័យអ្វីឡើយ ។ សូម ទាក់ទងស្ថាប័នហិរញ្ញវត្ថុរបស់អ្នក ដើម្បីសាកសួរឱ្យដឹងថា តើពួកគេបានទទួលសំបុត្របដិសេធពីទីភ្នាក់ងារ និយ័តកម្មរបស់ពួកគេហើយឬនៅ ។

**កម្មវិធីឥណទានក្រុមហ៊ុន:** ឥណទានសំរាប់គ្រោះមហន្តរាយតាមរយៈរដ្ឋបាលជំនួញខ្នាតតូច (SBA) មានសំរាប់ក្រុមហ៊ុនទាំងឡាយណា ដែលត្រូវការយកទៅជួសជុល ឬជំនួសសំភារៈ ស្តុក គ្រឿងម៉ាស៊ីន ឬ ឧបករណ៍ដទៃទៀតរបស់ក្រុមហ៊ុន ដែលត្រូវបានខូចខាត ឬបំផ្លាញ ។ ចំនួនឥណទានអតិបរមា គឺ $ 1,500,000.00 ។ បើសិនជាអ្នកត្រូវបានគេណែនាំដល់កម្មវិធីនេះ អ្នកនឹងទទួលបាន កញ្ចប់ពាក្យស្នើសុំមួយ នៅក្នុងប្រអប់សំបុត្ររបស់អ្នក ។ សំរាប់ព័ត៌មានបន្ថែម ឬជំនួយក្នុងការបំពេញសំណុំ បែបបទនេះ សូមមើលកញ្ចប់ពាក្យស្នើសុំ ឬគេហទំព័ររបស់ SBA www.sba.gov ។

**សេវាកម្មសំរាប់អ្នកប្រើប្រាស់:** ការផ្តល់ប្រឹក្សាក៏មានផងដែរចំពោះបញ្ហារបស់អ្នកប្រើប្រាស់ ដូចជា ការពុំមានលក់ផលិតផល និងសេវា ដែលចាំបាច់សំរាប់ការសាងសង់ឡើងវិញ ការឡើងតំលៃហួសហេតុ ការព្រួយបារម្ភណ៍ និងការអនុវត្តន៍ផ្សេងៗរបស់ក្រុមហ៊ុនដែលមិនមានកេរ្តិ៍ឈ្មោះ ។ល ។

**ការផ្តល់ប្រឹក្សាពីវិបត្តិ:** សេវាបង្អែក និងការផ្តល់ប្រឹក្សាអន្តរាគមន៍រយៈពេលខ្លី ក៏មានសំរាប់បញ្ហាសុខភាព ផ្លូវចិត្ត ដែលបណ្តាលឡើង ឬធ្វើឱ្យមានភាពធ្ងន់ធ្ងរដោយសារគ្រោះមហន្តរាយ ។

---

**ជំនួយសំរាប់អ្នកអត់មានការងារធ្វើដែលបណ្តាលមកពីគ្រោះមហន្តរាយ:** ជំនួយនេះ ផ្តល់ជូនការបង់អត្ថប្រយោជន៍ប្រចាំសប្តាហ៍ ទៅបុគ្គលទាំងឡាយណាដែលបានបាត់បង់ការងារដោយសារគ្រោះមហន្តរាយ រាប់បញ្ចូលទាំងអ្នកដែលធ្វើការឱ្យខ្លួនឯង កសិដ្ឋាន និងម្ចាស់កសិដ្ឋានចិញ្ចឹមសត្វ និងអ្នកដទៃទៀត ដែលពុំមាននៅក្នុងកម្មវិធីធានារ៉ាប់រងធម្មតាសំរាប់អ្នកអត់មានការងារធ្វើ ។

**ជំនួយសង្គ្រោះបន្ទាន់:** អាហារ សំលៀកបំពាក់ ជំរក និងជំនួយផ្នែកវេជ្ជសាស្ត្រជាបន្ទាន់ អាចត្រូវបានគេផ្តល់ឱ្យ ទៅឯកត្តបុគ្គល និងគ្រួសារទាំងឡាយ ដែលមានតំរូវការ ដោយសារលទ្ធផលនៃគ្រោះមហន្តរាយ ។ កាកបាទ ក្រហមអាមេរិក (American Red Cross - ARC) កងទ័ពជំនួយ (Salvation Army) ក្រុមធ្វើការតាមព្រះវិហារ និងអង្គការស្ម័គ្រចិត្តដទៃផ្សេងទៀត អាចផ្តល់ជំនួយនេះ ។

**ការប្រឹក្សាខាងផ្នែកហិរញ្ញវត្ថុ:** ផ្តល់ជូននូវការណែនាំ និងជំនួយខាងផ្នែកហិរញ្ញវត្ថុ និងសេដ្ឋកិច្ច ដល់ឯកត្តបុគ្គល និងក្រុមហ៊ុនតូចៗ ដែលទទួលរងគ្រោះដោយសារគ្រោះមហន្តរាយនានា ។ **អង្គការបង្រួបបង្រួមក្តីសង្ឃឹមអាមេរិក (Hope Coalition America)** ផ្តល់ជូននូវការប្រឹក្សាផ្នែកហិរញ្ញវត្ថុដោយឥតគិតថ្លៃ និងផ្តល់ឯកសារដ៏មានសារៈប្រយោជន៍ជាច្រើន ដូចជា "ជំនួយសង្គ្រោះបឋមផ្នែកសេដ្ឋកិច្ចនៅពេលមាន អាសន្ន" (Emergency Financial First Aid Kit)និង "មគ្គុទេសក៏ក្នុងការត្រៀមទុកជាមុនខ្លួនឯងសំរាប់គ្រោះមហន្តរាយ" (Personal Disaster Preparedness Guide) ។ ឯកសារទាំងអស់នេះ គឺមាន ហើយអាចទាញយកដោយឥតបង់ប្រាក់ពីគេហទំព័ររបស់ពួកគេ តាមអាសយដ្ឋាន www.operationhope.org ។ សំរាប់ព័តិមានបន្ថែម អ្នកអាចទៅលេខ: 1-888-388-4673 (HOPE) ។

**ការបន្ធូរបន្ថយការគ្រោះថ្នាក់:** អ្នកអាចទទួលបានមូលនិធិ ដើម្បីយកទៅបង្ការការពារការខូចខាតនៅពេលអនាគត ចំពោះរបស់របរប្រើប្រាស់សំខាន់ៗរបស់អ្នក (ចង្ក្រាន ម៉ាស៊ីនទឹក ប្រព័ន្ធភ្លើង) ដោយលើកវាឱ្យខ្ពស់ ឬប្តូរទីតាំងរបស់ទាំងអស់នោះ ទៅកន្លែងផ្សេងទៀតនៅក្នុងផ្ទះរបស់អ្នក ។

**កម្មវិធីឥណទានសំរាប់ផ្ទះ និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន:** ឥណទានសំរាប់គ្រោះមហន្តរាយ តាមរយៈរដ្ឋបាលជំនួញខ្នាតតូច (SBA) មានចំពោះម្ចាស់ផ្ទះ និងអ្នកជួល ដើម្បីស្តារ ឬជំនួសទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងអចលទ្រព្យ ដែលរងការខូចខាតនៅពេលមានគ្រោះមហន្តរាយ ។ ចំណែកនៃប្រាក់កម្ចីអតិបរមា

សំរាប់អចលនព្រទ្យគឺ $200,000.00 និងសំរាប់ទ្រព្យសម្បត្តិផ្ទាល់ខ្លួនគឺ $40,000.00 ។ ទំហំនៃប្រាក់កម្ចីគឺមានការកំណត់ចំពោះចំនួន នៃ ការខូចខាតដែលបានបញ្ជាក់ពី SBA ថាគ្មានធា នារ៉ាប់រង ។ បើសិនជាមានគេណែនាំអ្នកអំពីកម្មវិធីនេះ អ្នកនឹង ឃើញមានព័តិមានបន្ថែមទៀត នៅក្នុង "សេចក្តីសង្ខេបនៃពាក្យស្នើសុំ" នៅផ្នែកខាងក្រោយនៃសំណុំបែបបទ ដាក់ពាក្យស្នើសុំជំនួយសំរាប់គ្រោះមហន្តរាយ" ។

**ព័តិមានអំពីការធានារ៉ាប់រង:** ជំនួយ និង/ឬការប្រឹក្សា ក៏មានអំពីបញ្ហាធានារ៉ាប់រង និងសំណួរ ដែលប្រហែលជារាប់បញ្ចូលទាំងឯកសារអំពីគោលការណ៍ដែលបានបាត់បង់ជាច្រើនច្បាប់ ការរៀបចំឯកសារទាមទារ ការដោះស្រាយដោយរួសរាន់ ។ល ។ បើសិនជាអ្នកមិនអាចដោះស្រាយបញ្ហារបស់អ្នកជាមួយក្រុមហ៊ុនធានារ៉ាប់រងទេនោះ អ្នកអាចធ្វើការទាក់ទងទៅ អគ្គស្នងការធានារ៉ាប់រងរដ្ឋ (State Insurance Commissioner) ។ សំរាប់សំណួរទាក់ទងនឹងការធានារ៉ាប់រងគ្រោះមហន្តរាយដោយសារទឹកជំនន់ សូមទាក់ទងទៅ កម្មវិធីធានារ៉ាប់រងគ្រោះមហន្តរាយដោយទឹកជំនន់ជាតិ (National Flood Insurance Program - NFIP) ។

**សេវាផ្នែកច្បាប់:** សេវាផ្នែកច្បាប់ ឥតបង់ប្រាក់/ក្នុងតម្លៃថោក រាប់បញ្ចូលទាំងការផ្តល់យោបល់ផ្នែកច្បាប់ ការប្រឹក្សាយោបល់ និងការតំណាង អាចនឹងមានផ្តល់ជូនដល់ជនរងគ្រោះដោយសារគ្រោះមហន្តរាយ ដែលមានប្រាក់ចំណូលទាប ។

**សន្តិសុខសង្គម:** ជំនួយក៏មានពីរដ្ឋបាលសន្តិសុខសង្គមដែរ (Social Security Administration - SSA) ក្នុងការពន្លឿនមូលប្បទានប័ត្រ ដែលបានពន្យារដោយសារគ្រោះមហន្តរាយ ហើយសំរាប់ជំនួយក្នុងការដាក់ពាក់ស្នើសុំអត្ថប្រយោជន៍សំរាប់អ្នករួចផុតពីគ្រោះថ្នាក់ និងអ្នកមានកង្វះខាតសមត្ថភាព ។

**ជំនួយផ្នែកពន្ធសហព័ន្ធ:** ច្បាប់ព័ន្ធដាររបស់សហព័ន្ធ អនុញ្ញាតឱ្យសេវាប្រាក់ចំណូលផ្ទៃក្នុង (Internal Revenue Service - IRS) ផ្តល់នូវជំនួយដល់អ្នកបង់ពន្ធ ដែលជាជនរងគ្រោះនៃគ្រោះមហន្តរាយដែលប្រកាសដោយប្រធានាធិបតី ។ ជំនួយនេះរាប់បញ្ចូលទាំងការផ្អាកការកំណត់នៃការបង់ពន្ធ ដើម្បីទុកពេលឱ្យអ្នកបន្ថែមទៀតក្នុងការរៀបចំឯកសារ និងសងប្រាក់វិញមុនពេលគេតម្រូវឱ្យអ្នកបង់ការផាកពិន័យចំនួនបន្ថែម ឬការបូកបន្ថែមទៅលើពន្ធ ឬកាត់បន្ថយការប្រាក់សំរាប់រយៈពេលដែលអ្នកបានទទួលពេល បន្ថែម

ដើម្បីរៀបចំឯកសារសុំពន្ធវិចឹន និងបង់ពន្ធ ពីព្រោះអ្នកស្ថិតនៅក្នុងតំបន់ទទួលរងគ្រោះមហន្តរាយដែលបាន ប្រកាសដោយប្រធានាធិបតី ។

ជាទូទៅ សំណងជំនួយសំរាប់គ្រោះមហន្តរាយដែលមានលក្ខណៈពេញលេញ មិនត្រូវបានគេតំរូវឱ្យរាយការណ៍ នៅក្នុងប្រាក់ចំណេញសុទ្ធឡើយ ។ សំណងជំនួយសំរាប់គ្រោះមហន្តរាយដែលមានលក្ខណៈពេញលេញ រាប់ បញ្ចូលទាំងសំណងដែលបានទទួលពីប្រភពណាមួយ ដើម្បីយកមកបង់ការចំណាយសមហេតុសមផល និង សំរាប់ផ្ទាល់ខ្លួន គ្រួសារ ការរស់នៅ ឬបុណ្យសព ដែលជាលទ្ធផលនៃគ្រោះមហន្តរាយដែលបានប្រកាស ដោយប្រធានាធិបតី ។ IRS អាចអនុញ្ញាតឱ្យមានការខូចខាតទាំងឡាយណាដែលបានធ្វើឱ្យប៉ះពាល់ដល់ ផ្ទះ ទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងរបស់របរប្រើប្រាស់ក្នុងផ្ទះ ឱ្យគេកាត់ចេញពីពន្ធវិចឹនលើប្រាក់ចំណូល បើសិនជា ការខូចខាតទាំងនោះពុំមាននៅក្នុងធានារ៉ាប់រង ។ អ្នកបង់ពន្ធ ក៏អាចរៀបចំឯកសារស៊ីវិចឹន ដែលបានកែ ហើយ ដើម្បីទទួលបាននូវការសងថ្លៃពន្ធមានពេល ។ ព័ត៌មាន សំណុំបែបបទ និងការផ្សព្វផ្សាយបន្ថែម អាចរកបានពីគេហទំព័រ របស់ IRS តាមអាសយដ្ឋាន http://www.irs.gov/newsroom/article/0,,id=108362,00.html ។

**ជំនួយពន្ធផ្សេងទៀត:** អ្នកប៉ាន់ប្រមាណតំលៃពន្ធ អាចផ្តល់នូវព័ត៌មាន និងជំនួយ ស្តីអំពីជំនួយពន្ធលើទ្រព្យ សម្បត្តិតាមដែលអាចធ្វើទៅបាន ។

**អត្ថប្រយោជន៍របស់ទាហានចូលនិវត្តៈ** រដ្ឋបាលទាហានចូលនិវត្ត (Veterans Administration - VA) អាច បញ្ចូលព័ត៌មានស្តីអំពីអត្ថប្រយោជន៍ ប្រាក់សោធនិវត្ត ការដោះស្រាយខាងធានារ៉ាប់រង និង ឥណទាន អចលនទ្រព្យរបស់ VA ។

# សំណួរនិងចំលើយ ដែលគេសួរជាញឹកញាប់

1. **រង្វាន់សំរាប់ការគ្រប់គ្រងគ្រោះមហន្តរាយ: ទីភ្នាក់គ្រប់គ្រងគ្រោះមហន្តរាយរបស់សហព័ន្ធ** (Federal Emergency Management Agency – FEMA)

***តើអ្វីទៅជា FEMA ?*** FEMA គឺជាទីភ្នាក់ងារគ្រប់គ្រងគ្រោះមហន្តរាយរបស់សហព័ន្ធដែលមានតួនាទីទទួលខុសត្រូវក្នុងការផ្តល់ និងសម្របសម្រួលសេវាកម្មសង្គ្រោះបន្ទាន់នៅក្នុងតំបន់ទទួលរងដោយគ្រោះមហន្តរាយ ។ FEMA ធ្វើការជាដៃគូរជាមួយបណ្តាផ្នែកផ្សេងៗរបស់រដ្ឋាភិបាលសហព័ន្ធ រដ្ឋាភិបាលរបស់រដ្ឋនីមួយៗ និងអង្គការស្ម័គ្រចិត្តជាច្រើនទៀត ។

**តើមានប្រភេទនៃគំរោងផ្តល់ជំនួយសំរាប់គ្រោះមហន្តរាយអ្វីខ្លះ នៅក្នុងតំបន់ទទួលរងដោយគ្រោះមហន្តរាយ?** មានកម្មវិធីរបស់សហព័ន្ធបឋមពីរ ដែលផ្តល់ជំនួយសំរាប់គ្រោះមហន្តរាយៈ

- **កម្មវិធីផ្ទះសំបែងនិងឯកត្តបុគ្គល** របស់ FEMA ផ្តល់ថវិកា និងសេវាកម្មដោយផ្ទាល់ដល់បុគ្គលទាំងឡាយណាដែលទទួលរងដោយគ្រោះមហន្តរាយ ។ តម្រូវការជាច្រើនត្រូវតែបំពេញដើម្បី ធ្វើឱ្យមានគុណសម្បត្តិគ្រប់គ្រាន់សំរាប់ជំនួយពីកម្មវិធីនេះ ។

- **រដ្ឋបាលជំនួញខ្នាតតូចរបស់សហរដ្ឋអាមេរិក (U.S. Small Business Administration)** បានផ្តល់កំចីដោយយកការប្រាក់ទាប សំរាប់ការ ខូចខាតដល់ទ្រព្យសម្បត្តិរបស់ម្ចាស់ផ្ទះ អ្នកជួល ក្រុមហ៊ុនអាជីវកម្ម និងអង្គការ ឯកជន ដែលមិនទទួលកំរៃដែលមិនត្រូវបានទទួលនូវការធានារ៉ាប់រង ។

***តើការផ្តល់ជំនួយសំរាប់គ្រោះមហន្តរាយត្រូវការទូទាត់វិញដែរឬទេ?*** ថវិកាដែលទទួលបានតាមរយៈកម្មវិធីផ្ទះសំបែង និងឯកត្តបុគ្គលរបស់ FEMA គឺមិនចាំបាច់ត្រូវសងវិញទេ ។ កម្ចីពីរដ្ឋបាលជំនួញខ្នាតតូចគឺចាំបាច់ត្រូវតែសងវិញ ។

***តើខ្ញុំអាចដាក់ពាក្យសុំជំនួយសំរាប់រថយន្តដែលខូចខាតរបស់ខ្ញុំបានទេ?*** ប្រាកដជាបាន ។ អ្នកចាំបាច់ត្រូវផ្តល់ភស្តុតាងអំពីភាពជាម្ចាស់កម្មសិទ្ធិ និងព័ត៌មានអំពីការធានារ៉ាប់រង ។

***តើខ្ញុំអាចដាក់ពាក្យសុំជំនួយសំរាប់អាហារដែលបាត់បង់ដោយសារតែគ្រោះមហន្តរាយទេ?*** មិនបានទេ ។ អាហារ ដែលបាត់បង់មិនត្រូវបានរួមបញ្ចូលនៅក្នុងកម្មវិធីផ្ទះសំបែង និងឯកត្តបុគ្គល (IHP) ទេ ។ អង្គការស្ម័គ្រចិត្តមួយចំនួននៅក្នុងតំបន់ដែលរងគ្រោះដោយគ្រោះមហន្តរាយប្រហែលជាអាចផ្តល់អាហារដល់អ្នកបាន ។

***តើនឹងមានកម្មវិធីណាខ្លះដែលចេញថវិកាសំរាប់ចំណាយបន្លាស់ទី និងការស្តុកទុកទំនិញ?*** ចំណាយសំរាប់ការបន្លាស់ទី និងការស្តុបទំនិញ នឹងត្រូវបញ្ចូលនៅក្នុងកម្មវិធីផ្ទះសំបែង និងឯកត្តបុគ្គល ប្រសិនបើចំណាយទាំងនេះមានការពាក់ព័ន្ធនិងគ្រោះមហន្តរាយ ។ ចូរដាក់វិក្កយបត្រជូនទៅ IHP ដើម្បីចង់ដឹងថាតើការចំណាយទាំងនោះនឹងត្រូវបានរួមបញ្ចូលឬអត់ ។

***តើនឹងមានអ្វីកើតឡើងប្រសិនជាខ្ញុំដាក់ពាក្យសុំជំនួយទៅ FEMA ?*** នៅក្នុងរវាង ១០ថ្ងៃនៃការដាក់ពាក្យរបស់អ្នកទៅ FEMA ប្រសិនបើអ្នកមិនត្រូវបានធ្វើការធានា ឬខ្វះនូវការធានារ៉ាប់រងត្រឹមត្រូវអធិការកិច្ចដែលមាន លក្ខណៈសម្បត្តិគ្រប់គ្រាន់ នឹងទាក់ទងអ្នកដើម្បីរៀបចំពេលវេលាសំរាប់ត្រួតពិនិត្យមើលការខូចខាតដល់ទ្រព្យសម្បត្តិដែលបង្ករដោយគ្រោះមហន្តរាយ ។ ការបាត់បង់របស់អ្នកនឹងត្រូវបានកត់ត្រាទុក និងដាក់បញ្ជូន ទៅ IHP ។ នៅក្នុងរវាងជាង ១០ថ្ងៃនេះ អ្នកនឹងទទួលការការសំរេចចិត្តណាមួយពី IHP អំពីថាតើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សំរាប់ទទួលជំនួយពី IHP ដែរឬទេ ។ ប្រសិនបើគេបញ្ជូនអ្នកទៅសុំកម្ចីគ្រោះមហន្តរាយពីរដ្ឋបាលជំនួញខ្នាតតូច (SBA) SBA នឹង ធ្វើការទំនាក់ទំនងជាមួយអ្នក និង កំណត់ពេលវេលាណាត់ជួបដើម្បីពិនិត្យលើការបាត់បង់ដែលបង្កឡើង ដោយគ្រោះមហន្តរាយ ។

***តើវាត្រូវប្រើពេលប៉ុន្មានដើម្បីទទួលបានជំនួយគ្រោះមហន្តរាយពីរដ្ឋ / ពី FEMA?*** ប្រសិនបើអ្នកមានសិទ្ធិសំរាប់ទទួលជំនួយនេះ អ្នកគួរតែទទួលបាននូវការពិនិត្យរបស់រដ្ឋ ឬរតនាគាររបស់សហរដ្ឋអាមេរិក ឬការជូន

ដំណឹងអំពីប្រាក់បញ្ញើរបស់អ្នកនៅក្នុងគណនីធានាគាររបស់អ្នក ក្នុងកំឡុង១០ថ្ងៃ នៃការចុះទស្សនៈកិច្ចរបស់អ្នកត្រួតពិនិត្យ ។ ប្រភេទនៃជំនួយផ្សេងទៀតអាចនឹងត្រូវបានផ្តល់ជូននៅពេលក្រោយ អាស្រ័យលើសិទ្ធិស្របច្បាប់ជាក់ស្តែង និងតម្រូវការ ។

***ប្រសិនខ្ញុំមានសំណួរអំពីការដាក់ពាក្យរបស់ខ្ញុំ ឬចង់ផ្លាស់ប្តូរព័ត៌មានខ្លះដែលខ្ញុំបានផ្តល់ជូន តើខ្ញុំគួរធ្វើអ្វីខ្លះ?***
ចូរហៅទូរស័ព្ទទៅកាន់បណ្តាញទូរស័ព្ទទទួលបន្ទុកផ្នែកគ្រោះមហន្តរាយរបស់ 1-800-621-3362 (FEMA) (សំរាប់បុគ្គលគរថ្លង់: 1-800-462-7585) ឬចូលទៅកាន់គេហទំព័ររបស់យើង www.fema.gov ។

***ប្រសិនបើវាមានរយៈពេលជាង១២ថ្ងៃចាប់តាំងពីការចុះទស្សនកិច្ចរបស់អ្នកត្រួតពិនិត្យរបស់ FEMA និង ប្រសិនបើមិនបានទទួលព័ត៌មានណាមួយពី FEMA ទេ តើខ្ញុំគួរធ្វើយ៉ាងដូចម្តេច?*** ត្រូវហៅទូរស័ព្ទទៅកាន់បណ្តាញទូរស័ព្ទទទួលបន្ទុកផ្នែកគ្រោះមហន្តរាយរបស់ FEMA 1-800-621-3362 (FEMA) (សំរាប់បុគ្គលគរថ្លង់: 1-800-462-7585) ឬចូរគេហទំព័ររបស់យើង www.fema.gov ដើម្បីពិនិត្យលើស្ថានភាពនៃការដាក់ពាក្យរបស់អ្នក ។ ប្រសិនបើមានមជ្ឈមណ្ឌល ស្តារគ្រោះមហន្តរាយ (Disaster Recovery Center – DRC) នៅក្នុងតំបន់របស់អ្នក អ្នកអាចសាកសួរព័ត៌មាននៅទីនោះអំពីការដាក់ពាក្យរបស់អ្នក ។

***ប្រសិនបើខ្ញុំមិនឯកភាពនឹងលទ្ធផលនៃការត្រួតពិនិត្យ ឬចំនួនថវិកាដែលខ្ញុំបានទទួល តើខ្ញុំគួរធ្វើអ្វីខ្លះ?***
អ្នកអាចសុំឱ្យមានការសំរេចចិត្ត ។ នីតិវិធីសំរាប់ធ្វើការស្នើសុំត្រូវបានបង្កើតឡើងនៅក្នុងសៀវភៅមគ្គុទេសក៍ (ទំព័រទី១៥) ឬអ្នកអាចហៅទូរស័ព្ទមកកាន់បណ្តាញទូរស័ព្ទទទួលបន្ទុកផ្នែកគ្រោះមហន្តរាយរបស់ FEMA 1-800-621-3362 (FEMA) (សំរាប់បុគ្គលគរថ្លង់: 1-800-462-7585) សំរាប់ព័ត៌មានអំពីដំណើរការនៃការស្នើសុំ ។

### *តើប្រភេទនៃឯកសារកម្មសិទ្ធិអ្វីខ្លះដែលខ្ញុំអាចផ្តល់ឱ្យដើម្បីគាំទ្រដល់ការដាក់ពាក្យសុំជំនួយរបស់ខ្ញុំ?*

ខាងក្រោមនេះគឺជាប្រភេទឯកសារមួយចំនួនដែលអាចផ្តល់សំរាប់បង្ហាញអំពីកម្មសិទ្ធិរបស់អ្នក:

- លិខិតកាត់កម្មសិទ្ធិ ឬកំណត់ត្រាជាផ្លូវការណាមួយនោះ អាចយកមកធ្វើជាច្បាប់ដើម ឬជាលិខិតកាន់កាប់ទ្រព្យសម្បត្តិដែលចុះបញ្ជីអ្នកជាម្ចាស់ស្របច្បាប់។
- លេខប័ណ្ណកម្មសិទ្ធិ ដែលចុះបញ្ជីអ្នកនៅលើឯកសារបញ្ចើទុកក្នុងដៃតតិយជន ឬឯកសារសំគាល់កម្មសិទ្ធិទិញលំនៅដ្ឋាន។
- សៀវភៅសងបំណុល ឬឯកសារបំណុលផ្សេងៗ (ដូចជា: ការជូនដំណឹងអំពីការបង់ប្រាក់យឺត ការជូនដំណឹងអំពីការទាញយកសិទ្ធិជាម្ចាស់) អាចយកមកប្រើដើម្បីបញ្ជាក់អំពីភាពជាម្ចាស់កម្មសិទ្ធិ នៅពេលណាឈ្មោះរបស់អ្នកត្រូវបានចុះក្នុងបញ្ជី អមជាមួយនិងអាសយដ្ឋានទីលំនៅដែលទទួលរងការខូចខាតរបស់អ្នក។
- ការធានារ៉ាប់រងលើទ្រព្យសម្បត្តិពិតប្រាកដ គឺធ្វើសំរាប់តែលំនៅដ្ឋានដែលទទួលរងការខូចខាតដែលឈ្មោះរបស់អ្នកត្រូវបានចុះបញ្ជីជាអ្នកដែលត្រូវបានទទួលការធានារ៉ាប់រង។
- វិក្កយបត្រ ពន្ធ ឬ វិក្កយបត្រ បង់ពន្ធលើទ្រព្យសម្បត្តិ ដែលបង្ហាញអំពីទីលំនៅដែលទទួលរងការខូចខាត និងដែលចុះបញ្ជីអ្នកជាភាគីទទួលខុសត្រូវទៅសំរាប់ការវាយតម្លៃ។

### *តើប្រភេទនៃឯកសារដែលនៅមានណាទៀតដែលខ្ញុំអាចផ្តល់ឱ្យដើម្បីគាំទ្រការដាក់ពាក្យសុំជំនួយរបសខ្ញុំ?*

ខាងក្រោមនេះ គឺជាប្រភេទនៃឯកសារមួយចំនួន ដែលអ្នកអាចផ្តល់ជូន ដើម្បីបង្ហាញអំពីពេលវេលាកាន់កាប់:

- វិក្កយបត្រទឹក ឧស្ម័ន និងភ្លើង សំរាប់លំនៅដ្ឋានដែលទទួលរងការខូចខាត ដែលមានឈ្មោះរបស់អ្នក (ឬឈ្មោះរបស់អ្នកដាក់ពាក្យ)។ វិក្កយបត្រនេះគឺសំរាប់ការប្រើប្រាស់ធំៗមួយចំនួន ដូចជា ទឹក ឧស្ម័ន និងភ្លើង។
- របាយការណ៍ជំនួញ ដែលបានផ្ញើរទៅកាន់លំនៅដ្ឋានដែលទទួលរងការខូចខាតដោយមានឈ្មោះរបស់អ្នក (ឬឈ្មោះរបស់អ្នកសហបេក្ខជន)។ របាយការណ៍ជំនួញ រួមមាន: វិក្កយបត្រប្រើប្រាស់ប័ណ្ណឥណទាន បញ្ជីប្រគល់ទំនិញ ឬសំបុត្រដែលត្រូវបានផ្ញើរមកអ្នក ដោយមានបង្ហាញអាសយដ្ឋានទីលំនៅដែលបានទទួលរងការខូចខាត។

- <u>របាយការណ៍របស់និយោជិត</u> ដែលបានផ្ញើរទៅលំនៅដ្ឋានដែលទទួលរងការខូចខាត ដែលមានឈ្មោះរបស់អ្នក (ឬឈ្មោះរបស់សហបេក្ខជន) ។ របាយការណ៍របស់និយោជិតសំដៅទៅលើកន្ទុយសន្លឹកវិក្កយបត្រប្រាក់ខែ និងឯកសារស្រដៀងគ្នាដែលបានផ្ញើរមកអ្នក ហើយមានបង្ហាញអាសយដ្ឋានទីលំនៅដែលទទួលរងការខូចខាត ។
- <u>ប័ណ្ណបើកបរ និងប័ណ្ណរបស់អ្នកមិនមែនជាអ្នកបើកបរ</u> ដែលបង្ហាញពីអាសយដ្ឋានទីលំនៅដែលទទួលរងការខូចខាត ។

***តើខ្ញុំអាចទទួលព័ត៌មានអំពីការធានារ៉ាប់រងពីគ្រោះទឹកជំនន់ពីកន្លែងណាបាន?*** ចូរហៅទូរស័ព្ទមកកាន់ទីភ្នាក់ងារធានារ៉ាប់រងខាងផ្នែកទ្រព្យសម្បត្តិ ឬផ្នែកគ្រោះថ្នាក់ដែលមានអជ្ញាប័ណ្ណត្រឹមត្រូវ ឬអាចហៅទូរស័ព្ទមកកម្មវិធីធានារ៉ាប់រងគ្រោះទឹកជំនន់ជាតិតាមលេខ 1-800-427-4661 ។

***តើខ្ញុំគួរតែសំអាតគេហដ្ឋានរបស់ខ្ញុំដែរឬទេ មុននឹងមានការចុះមកត្រួតពិនិត្យ?*** អ្នកគួរតែធ្វើការសំអាតជាមុនសិន មុននឹងមានការចុះមកត្រួតពិនិត្យ ។ ប្រសិនបើអាចធ្វើទៅបាន អ្នកអាចថតរូបនូវរាល់ការខូចខាតនានា មុនធ្វើការសំអាត ។

***តើខ្ញុំគួរតែរក្សារទុកវិក្កយបត្ររបស់ខ្ញុំដែរឬទេ?*** អ្នកត្រូវរក្សារទុកនូវរាល់វិក្កយបត្រចំណាយរបស់អ្នកទាំងអស់ ។

2. **កម្ចីសំរាប់គ្រោះមហន្តរាយៈ រដ្ឋបាលជំនួញខ្នាតតូចរបស់សហរដ្ឋអាមេរិក (U.S. Small Business Administration, SBA):**

***ហេតុអ្វីខ្ញុំត្រូវទទួលសំណុំបែបបទដាក់ពាក្យសុំកម្ចីសំរាប់គ្រោះមហន្តរាយពី SBA បន្ទាប់ពីដាក់ពាក្យសុំទៅ FEMA ?*** SBA គឺជាប្រភពដំបូងនៃមូលនិធិសហព័ន្ធសំរាប់ជំនួយសង្គ្រោះរយៈពេលវែងសំរាប់ជនរងគ្រោះដោយទឹកជំនន់ ។ សំរាប់ការខូចខាតដោយគ្រោះមហន្តរាយទៅលើទ្រព្យសម្បត្តិឯកជនរបស់ម្ចាស់ផ្ទះ អ្នកជួល និងអាជីវកម្មដែលមិនមានលក្ខណៈជាកសិដ្ឋាន ដែលមិនមានស្ថិតនៅក្រោមការធានារ៉ាប់រងពេញលេញ នោះប្រភេទជាមូលដ្ឋាននៃជំនួយរបស់សហព័ន្ធ គឺជាកម្ចីគ្រោះមហន្តរាយដែលយកការប្រាក់ទាបពី SBA ។

ដោយមានការផ្តល់ប្រាក់កម្ចីដែលអាចលៃលកបាន កម្មវិធីប្រាក់កម្ចីគ្រោះមហន្តរាយរបស់ SBA បានជួយដល់ជនរងគ្រោះដោយគ្រោះមហន្តរាយ ក្នុងការទូទាត់លើការជួសជុល ខណៈដែលរក្សារទុកការចំណាយសមល្មមសំរាប់អ្នកជាប់ពន្ធដារ ។

***តើខ្ញុំរកជំនួយក្នុងការបំពេញបែបបទស្នើសុំកម្ចីគ្រោះមហន្តរាយរបស់ SBA ដោយរបៀបណា?*** SBA មានមន្ត្រីកម្ចីនៅក្នុងការិយាល័យផ្នែកគ្រោះមហន្តរាយក្នុងតំបន់របស់ SBA សំរាប់ផ្តល់សេវាកម្មដោយផ្ទាល់ដល់ជនរងគ្រោះដោយគ្រោះមហន្តរាយ ។ អ្នកអាចមកកាន់ SBA នៅគ្រប់ទីស្នាក់ការនានា ដោយពុំចាំបាច់ធ្វើការណាត់ជួបទេ ។ តំណាងរបស់ SBA មានក្តីសោមនស្សរីករាយក្នុងការឆ្លើយសំណួរ និងជួយបំពេញពាក្យស្នើសុំរបស់អ្នក ។ ដើម្បីចង់ដឹងថាការិយាល័យផ្នែកគ្រោះមហន្តរាយរបស់ SBA នៅកន្លែងណានោះ អ្នកអាចហៅទូរស័ព្ទមកកាន់លេខ 1-800-488-5323 ។

***ប្រសិនខ្ញុំបានទទួលមូលប្បទានប័ត្រពី FEMA ប៉ុន្តែវាមិនគ្រាប់គ្រាន់សំរាប់ទូទាត់រាល់ការជួសជុលនូវការខូចខាតដែលបង្កឡើងដោយគ្រោះមហន្តរាយ តើខ្ញុំអាចសុំជំនួយច្រើនជាងនេះទៀតបានទេ?*** ប្រាកដជាបាន ។ កម្ចីគ្រោះមហន្តរាយរបស់ SBA គឺមានគ្រប់គ្រាន់សំរាប់រួមបញ្ចូលចំណាយលើការជួលជុល ដែលពុំទាន់ត្រូវបានគេទូទាត់សងពេញលេញ ។ ការដាក់ពាក្យសុំត្រូវដាក់ទៅ SBA ដើម្បីសុំចំនួនទឹកប្រាក់បន្ថែមសំរាប់ភាពចាំបាច់នានា ។

***ខ្ញុំគិតថាខ្ញុំអាចទូទាត់លើការជួលជុលដោយខ្លួនឯងបាន តើខ្ញុំត្រូវតែដាក់ពាក្យសុំកម្ចីគ្រោះមហន្តរាយដែរឬទេ?*** អ្នកអាចរកឃើញថា តម្លៃសរុបសំរាប់ការជួសជុលទាំងមូលដោយខ្លួនឯងគឺច្រើនជាងអ្វីដែលអ្នកបានគ្រោងទុក ។ ដោយមានកម្ចីរបស់ SBA ដែលបានអនុម័តហើយនោះ អ្នកនឹងដឹងថា មូលនិធិសំរាប់ការជួសជុលទាំងស្រុងនោះគឺមាន ។ នៅពេលដែលគ្មានជនណាម្នាក់ចង់ជំពាក់បំណុលបន្ថែមនោះ កម្ចីដែលយកការប្រាក់ទាបគឺជាជំរើសមួយដែលប្រសើរជាងការធ្វើការជួសជុលទាំងស្រុង ។

***តើមានអ្វីកើតឡើង ប្រសិនខ្ញុំមិនអាចលៃលកសុំប្រាក់កម្ចីដើម្បីជួសជុលទ្រព្យសម្បត្តិដែលបានខូចខាត?*** ប្រសិន SBA កំណត់ថាអ្នកមិនអាចធ្វើការលៃលកសុំប្រាក់កម្ចីបានទេ SBA នឹងបញ្ជូនអ្នកដោយស្វ័យប្រវត្តិទៅ FEMA ដើម្បីសុំជំនួយបន្ថែម ។ FEMA អាចនឹងផ្តល់ថវិកាសំរាប់តម្រូវការនៅក្នុងគេហដ្ឋានរបស់អ្នក

ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ជំនួយបន្ថែមនេះ គឺមិនមានសំរាប់អាជីវកម្មផ្សេងទៀតនោះទេ។ ជំនួយបន្ថែមរបស់ FEMA គឺមានគោលបំណងបំពេញនូវការចំណាយចាំបាច់ និងតម្រូវការដទៃទៀតដែលមិនបានបំពេញតាមរយៈប្រ ភេទនៃជំនួយ រួមមានការធានារ៉ាប់រង និងប្រាក់កម្ចីគ្រោះមហន្តរាយ SBA ។ **ចូរចាំថា** ប្រសិនបើអ្នកត្រូវបានគេបញ្ជូនសំណុំបែបបទកម្ចីគ្រោះមហន្តរាយមកឱ្យ នោះ SBA នឹងមិនបញ្ជូនអ្នកត្រលប់ទៅ FEMA ទេ លុះត្រាតែពាក្យសុំកម្ចីដែលបានបំពេញហើយនោះ ត្រូវបានប្រគល់ត្រលប់ទៅ SBA វិញ ហើយ SBA បាន កំណត់ថា អ្នកមិនអាចសុំកម្ចីបានទេ។ អ្នកមិនចាំបាច់ដាក់បញ្ជូនពាក្យសុំកម្ចី SBA ទៅឱ្យគេពិចារណាសំរាប់ ជំនួយជួលលំនៅដ្ឋានដែលផ្តល់ជូនដោយ FEMA ទេ។

### 3. សិទ្ធិពលរដ្ឋរបស់អ្នក និងជំនួយសំរាប់គ្រោះមហន្តរាយ

***តើទំរង់នៃការរើសអើងណាខ្លះដែលច្បាប់ស្តីអំពីសិទ្ធិពលរដ្ឋបានហាមឃាត់?*** មានទំរង់នៃការរើសអើងមិនស្របច្បាប់មួយចំនួន ដែលបានកំណត់ឱកាសរបស់ប្រជាជនក្នុងការទទួលបាននូវមធ្យោបាយឈានទៅរកសេវាកម្ម និងកម្មវិធីនានា។ ក្នុងចំណោមសេវាកម្ម និងកម្មវិធីទាំងនោះ ក្នុងការប្រតិបត្តិកម្មវិធី ដែលគាំទ្រដោយ FEMA ភាគីទទួល (រដ្ឋ ឬទីភ្នាក់ងាររដ្ឋាភិបាលប្រចាំតំបន់ ដែលបានទទួលមូលនិធិគ្រោះមហន្តរាយរបស់សហព័ន្ធពី FEMA) មិនអាចធ្វើទៅបាន ដោយអាស្រ័យលើ ជាតិសាសន៍ ពណ៌សម្បុរ សាសនា សញ្ជាតិ ភេទ អាយុ ឬស្ថានភាពសេដ្ឋកិច្ច ទោះបីដោយផ្ទាល់ឬតាមមធ្យោបាយដែលឈរលើ កិច្ច សន្យាក៏ដោយ:

- បដិសេធនូវរាល់សេវាកម្ម ជំនួយ ឬអត្ថប្រយោជន៍ជាច្រើន
- ផ្តល់នូវសេវាកម្មផ្សេងៗពីគ្នា ជំនួយ ឬអត្ថប្រយោជន៍ ឬផ្តល់ឱ្យពួកគេក្នុងលក្ខណៈមួយដែលខុសគ្នាជាងការដែលសេវាកម្មជំនួយ ឬអត្ថប្រយោជន៍ទាំងនេះត្រូវបានផ្តល់អោយអ្នកដទៃ។
- ដាក់បុគ្គលទាំងនេះឱ្យនៅដាច់ដោយឡែក ក្នុងលក្ខណៈណាមួយដែលពាក់ព័ន្ធទៅនិងការទទួលសេវាកម្ម ជំនួយ ឬអត្ថប្រយោជន៍។

បំរាមទាំងនេះក៏បានអនុវត្តចំពោះ FEMA ខ្លួនឯងផងដែរ ក្នុងការប្រតិបត្តិកម្មវិធីរបស់សហព័ន្ធ។

***យ៉ាងដូចម្តេចវិញប្រសិនខ្ញុំមានបណ្តឹងសិទ្ធិពលរដ្ឋ?*** ទីភ្នាក់ងារសហព័ន្ធនិមួយៗ ដែលផ្តល់ជំនួយហិរញ្ញវត្ថុរបស់សហព័ន្ធមានតួនាទីទទួលខុសត្រូវលើការស៊ើបអង្កេតបណ្តឹងពីភាពរើសអើង ក្នុងការប្រើប្រាស់មូលនិធិរបស់ខ្លួន ។ ប្រសិនអ្នកជឿថាអ្នក ឬអ្នកដទៃដែលត្រូវបានទទួលការការពារពីច្បាប់សិទ្ធិពលរដ្ឋត្រូវបានគេរើសអើងប្រឆាំងទៅនឹងការទទួលជំនួយគ្រោះមហន្តរាយនោះ អ្នកអាចធ្វើការទំនាក់ទំនងមកបុគ្គលិកផ្នែកសិទ្ធិស្មើភាពគ្នា (Equal Rights Officers – ERO) របស់ FEMA ដែលមានតួនាទីធានានូវមធ្យោបាយស្មើភាពគ្នាចំពោះកម្មវិធីគ្រោះ មហន្តរាយរបស់ FEMA ។ ERO មានបំណងដោះស្រាយបញ្ហារបស់អ្នក ។ អ្នកអាចធ្វើការទំនាក់ទំនង ERO ដោយហៅទូរស័ព្ទមកកាន់លេខ 1-800-621-3362 (1-800-621-3362) (FEMA) ឬ TTY 1-800-462-7585 ។

ប្រសិនបើបញ្ហាមិនត្រូវបានដោះស្រាយ អ្នកអាចដាក់ពាក្យបណ្តឹងទៅ FEMA ។ ពាក្យបណ្តឹងដែលសរសេរជាលាយលក្ខអក្សរ និងចុះហត្ថលេខា គួរតែត្រូវបានផ្ញើរទៅកាន់ការិយាល័យធានាសិទ្ធិស្មើគ្នា (Office of Equal Rights) ជាទូទៅគឺស្ថិត នៅក្នុងរយៈពេល១៨០ថ្ងៃនៃកាលបរិច្ឆេទដែលភាពរើសអើងដែលត្រូវបានចោទប្រកាន់ ។ ពាក្យបណ្តឹងនេះត្រូវរួមមាន:

- ឈ្មោះរបស់អ្នក អាសយដ្ឋាន លេខទូរស័ព្ទ ។ ពាក្យបណ្តឹងរបស់អ្នកត្រូវមានការចុះហត្ថលេខា ។ ប្រសិនបើអ្នកដាក់ពាក្យបណ្តឹងជំនួសឱ្យនណាម្នាក់នោះ ត្រូវរួមបញ្ចូលឈ្មោះរបស់អ្នក អាសយដ្ឋាន លេខទូរស័ព្ទ និងទំនាក់ទំនងរបស់អ្នកជាមួយមនុស្សម្នាក់ផ្សេងទៀត (ឧទាហរណ៏ មិត្តភ័ក្រ មេធាវី ឪពុកម្តាយ ។ល ។)
- ឈ្មោះ និងអាសយដ្ឋានរបស់ទីភ្នាក់ងារ ស្ថាប័ន ឬផ្នែកដែលអ្នកជឿថាមានភាពរើសអើងចំពោះអ្នក ។
- ថាតើដោយវិធីណា ហេតុអ្វី និងនៅពេលណា ដែលអ្នកជឿថាមានភាពរើសអើងចំពោះអ្នក ។ ចូររួមបញ្ចូលព័ត៌មានអោយបានច្រើនដូចដែលអាចធ្វើទៅបានអំពីទង្វើនៃការរើសអើសដែលត្រូវបានគេចោទប្រកាន់ ។ ចូរបញ្ចូលឈ្មោះរបស់បុគ្គលដែលអ្នកចោទប្រកាន់ថាបានសំដែងនូវភាពរើសអើងចំពោះអ្នក ប្រសិនណាអ្នកស្គាល់ពួកគេ ។

- ប្រសិនបើអាចស្គាល់ ចូរប្រាប់ឈ្មោះបុគ្គលណាដែល FEMA អាចធ្វើការទំនាក់ទំនងបាន សំរាប់ព័ត៌មានបន្ថែមដើម្បីគាំទ្រ ឬបញ្ជាក់អំពីការចោទប្រកាន់របស់អ្នកអំពីភាពរើសអើង នៅក្នុងដំណើរការកម្មវិធីរបស់សហព័ន្ធ ។

***តើFEMA ធ្វើអ្វីខ្លះជាមួយនិងពាក្យបណ្តឹងនេះ?*** នៅពេលពាក្យបណ្តឹងត្រូវបានដាក់ វានឹងត្រូវបានទទួលការត្រួតពិនិត្យដោយ FEMA ដើម្បីកំណត់ថាតើវាមានយុត្តាធិការដើម្បីធ្វើការអង្កេតបញ្ហាដែលអ្នកបានលើកឡើងឬអត់ ។ ប្រសិនបើពាក្យបណ្តឹងរបស់អ្នកត្រូវបានគេទទួលយក FEMA នឹងធ្វើការអង្កេតលើពាក្យបណ្តឹងនោះ ហើយនឹងព្យាយាមដោះស្រាយនូវរាល់ការបំពាននានាប្រសិនបើត្រូវបានរកឃើញ ។ ប្រសិនការចរចារ ដើម្បីកែប្រែការបំពាននោះមិនទទួលជោគជ័យទេ នីតិវិធីច្បាប់អាចនឹងត្រូវបានអនុវត្ត ។

***យ៉ាងដូចម្តេចវិញប្រសិនបើខ្ញុំត្រូវបានគេតបតវិញ ប្រឆាំងនឹងការអះអាងអំពីសិទ្ធិរបស់ខ្ញុំ ឬប្រឆាំងនិងការដាក់ពាក្យបណ្តឹង?*** អ្នកគួរតែដឹងថា អ្នកទទួល ឬទីភ្នាក់ងារសហព័ន្ធត្រូវបានរារាំងពីការតបតប្រឆាំងអ្នក ឬបុគ្គលណាម្នាក់ផ្សេងទៀត ពីព្រោះគាត់បានប្រឆាំងនឹងគោលនយោបាយ ឬការអនុវត្តន៍ដែលគ្មានច្បាប់ទំលាប់ត្រឹមត្រូវ ឬធ្វើការចោទប្រកាន់ ឬចូលរួមក្នុងចាត់វិធានការបណ្តឹងតាមច្បាប់សិទ្ធិពលរដ្ឋ ។ ប្រសិនអ្នកជឿថាអ្នកត្រូវបានគេធ្វើតបតប្រឆាំងនឹងអ្នកវិញនោះ អ្នកគួរតែទាក់ទងមកកាន់ ការិយាល័យសិទ្ធិស្មើភាពគ្នា (Office of Equal Rights) របស់ FEMA ភ្លាម ។

# ការបរិយាយអំពីមូលហេតុនៃភាពមិនមានសិទ្ធិ

## 1. ការសំរេចចិត្តដំបូង

**I69B – ភាពគ្មានសិទ្ធិ – ការចុះហត្ថលេខា ដែលមិនបានទទួល (៩0 – ៦៩ B):** យោងទៅតាមកំណត់ត្រារបស់ FEMA គ្មានសំណុំបែបបទចេញផ្សាយ ឬសេចក្តីប្រកាសដែលត្រូវបានចុះហត្ថលេខាណាមួយ (៩0–៦៩B) សំរាប់ការដាក់ពាក្យមាននៅក្នុងឯកសារដែលរក្សាទុកទេ ។ ទំរង់បែបបទនេះពិតជាត្រូវការចាំបាច់ មុននឹង FEMA អាចផ្តល់ជំនួយ ។

**IAW – ភាពគ្មានសិទ្ធិ – អាសយដ្ឋានដូចគ្នា:** យោងទៅតាមកំណត់ត្រារបស់ FEMA នៅពេលមានគ្រោះមហន្តរាយ បេក្ខជនដែលកំពុងកន្លែងដែលមានអាសយដ្ឋានដូចអ្នកដែលបានដាក់ពាក្យសុំរួចហើយសំរាប់ជំនួយលំនៅដ្ឋានពី FEMA ។ FEMA អាចផ្តល់ត្រឹមតែជំនួយសំរាប់ការដាក់ពាក្យតែមួយសំរាប់អាសយដ្ឋានតែមួយប៉ុណ្ណោះ ។

**IDUPA – ភាពគ្មានសិទ្ធិ – ការចុះឈ្មោះជាន់គ្នា:** យោងទៅតាមកំណត់ត្រារបស់ FEMA បេក្ខជនមានពាក្យសុំជំនួយសំរាប់គ្រោះមហន្តរាយនៅក្នុងបញ្ជីឯកសាររួចស្រាច់ហើយ ។ FEMA អាចពិចារណាការដាក់ពាក្យសុំតែមួយគត់ពីបេក្ខជនម្នាក់ ។

**IID – ភាពគ្មានសិទ្ធិ – ការខូចខាតតិចតួច:** យោងទៅតាមការពិនិត្យរបស់ FEMA ប្រសិនបើរកឃើញថាគេហដ្ឋានដែលរងខូចខាតដោយគ្រោះមហន្តរាយរបស់បេក្ខជនអាចប្រើប្រាស់ស្នាក់នៅបានដោយសុវត្ថិភាព ។ ការកំណត់នេះ គឺ អាស្រ័យទៅលើការខូចខាតលើគេហដ្ឋានដែលពាក់ព័ន្ធនឹងគ្រោះមហន្តរាយ ។

**IIDV – ភាពគ្មានសិទ្ធិ – ការផ្ទៀងផ្ទាត់មើលអត្តសញ្ញាណដែលបានបាត់បង់:** មុននឹងយើងអាចធ្វើការពិចារណាលើការដាក់ពាក្យសុំជំនួយសំរាប់គ្រោះមហន្តរាយ FEMA ត្រូវធ្វើការផ្ទៀងផ្ទាត់ ព័ត៌មានដែលមាននៅលើពាក្យសុំ ។ នៅពេលនេះផងដែរ យើងមិនអាចតម្រូវឱ្យដូចគ្នានូវឈ្មោះរបស់ បេក្ខជន និងលេខសុវត្ថិភាពសង្គម ដើម្បីធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណ ។

**IMI – ភាពគ្មានសិទ្ធិ – ការត្រួតពិនិត្យដែលមិនបានធ្វើ:** យោងតាមកំណត់ត្រារបស់យើង បេក្ខជនមិនបានរក្សាការណាត់ជួបជាមួយអ្នកត្រួតពិនិត្យរបស់ FEMA ទេ។ ក្នុងគោលបំណង ដើម្បីឱ្យគេពិចារណាសំរាប់ជំនួយគេហដ្ឋាន FEMA បេក្ខជន (ឬសមាជិកក្នុងផ្ទះដែលមានអាយុលើសពី ១៨ឆ្នាំ) ត្រូវជួបជាមួយអ្នកត្រួតពិនិត្យដើម្បីវាយតម្លៃការខូចខាតដល់លំនៅដ្ឋានដែលបង្កដោយគ្រោះមហន្តរាយ។ នៅក្នុងពេលនេះដែរ បេក្ខជនមិនមានសិទ្ធិដើម្បីទទួលនូវការពិចារណាសំរាប់ជំនួយលំនៅដ្ឋានពី FEMA ឡើយ។

**INCI – ភាពគ្មានសិទ្ធិ – គ្មានការត្រួតពិនិត្យលើទំនាក់ទំនង:** អ្នកត្រួតពិនិត្យរបស់ FEMA មិនអាចទាក់ទងបេក្ខជនដើម្បីកំណត់ពេលវេលាណាត់ជួប។ ក្នុងគោលបំណងដើម្បីឱ្យគេពិចារណាសំរាប់ជំនួយលំនៅដ្ឋាន FEMA បេក្ខជន (ឬសមាជិកនៅក្នុងផ្ទះដែលមានអាយុលើសពី ១៨ឆ្នាំ) ត្រូវជួបជាមួយអ្នកត្រួតពិនិត្យដើម្បី ធ្វើការវាយតម្លៃការខូតខាតលំនៅដ្ឋានដែលបង្ករដោយគ្រោះមហន្តរាយ។ នៅក្នុងពេលនេះ បេក្ខជននេះគ្មាន សិទ្ធិដើម្បីឱ្យគេពិចារណាសំរាប់ជំនួយពី FEMA ទេ។

**INFI – ភាពគ្មានសិទ្ធិ – ការធានារ៉ាប់រងគ្រោះទឹកជំនន់:** យោងទៅតាមកំណត់ត្រារបស់យើង គេហដ្ឋានដែលបេក្ខជនបានរស់នៅ ខណៈពេលមានគ្រោះមហន្តរាយ គឺត្រូវបានរួមបញ្ចូលនៅក្នុងការធានារ៉ាប់រងគ្រោះទឹកជំនន់។ នៅក្នុងពេលនេះដែរ បេក្ខជនគ្មានសិទ្ធិសុំជំនួយសំរាប់ការខូចខាតគេហដ្ឋានដែលត្រូវបានរួមបញ្ចូលនៅក្នុងការធានារ៉ាប់រងគ្រោះទឹកជំនន់ឡើយ។

**INI – គ្មានសិទ្ធិ – ការធានារ៉ាប់រង (ដោយមានការត្រួតពិនិត្យ):** យោងតាមកំណត់ត្រារបស់យើង គេហដ្ឋានដែលបេក្ខជនបានរស់នៅ ខណៈពេលមានគ្រោះមហន្តរាយ គឺត្រូវបានរួមបញ្ចូលនៅក្នុងការធានារ៉ាប់រងគ្រោះទឹកជំនន់។ ការខូចខាតនានាដែលបានបង្ហាញនៅក្នុងការត្រួតពិនិត្យរបស់ FEMA គួរតែត្រូវបានរួមបញ្ចូលនៅក្នុងការធានារ៉ាប់រងរបស់បេក្ខជន។ FEMA មិនអាចផ្តល់ជំនួយណាដែលអាចរកបានពីប្រភពមួយផ្សេងទៀត រួមទាំងការធានារ៉ាប់រង។ ហេតុដូច្នេះហើយ បេក្ខជនគ្មានសិទ្ធិដើម្បីទទួលជំនួយសំរាប់ជួលជុលលំនៅដ្ឋាន ឬសំរាប់ផ្លាស់ទីលំនៅពី FEMA នៅក្នុងពេលនេះទេ។ បេក្ខជនគួរតែដាក់ពាក្យទាមទារទៅទីភ្នាក់ងារធានារ៉ាប់រងឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ពីព្រោះ FEMA អាចជួយដល់ការបាត់បង់នានា ដែលមិនត្រូវបានរួមបញ្ចូលនៅក្នុងការធានារ៉ាប់រង។

**INO – ការប្ដឹងឧទ្ធរណ៍ – ភាពគ្មានសិទ្ធិ –**
**ការធានារ៉ាប់រងដែលរួមបញ្ចូលការចំណាយក្នុងការរស់នៅប្រចាំថ្ងៃ:**
យោងតាមព័ត៌មានដែលបេក្ខជនបានដាក់ពាក្យមក ការធានារ៉ាប់រងដែលគាត់មានសំរាប់លំនៅដ្ឋានរបស់គាត់ ផ្ដល់នូវមូលនិធិសំរាប់ជួលលំនៅដ្ឋានសំរាប់រស់នៅបណ្ដោះអាសន្ន ខណៈពេលការជួលជុលលំនៅដ្ឋានកំពុងដំណើរការ ។ យើងមិនទាន់បានទទួលឯកសារដែលបង្ហាញថាបេក្ខជនបានប្រើប្រាស់នូវមូលនិធិដែលមានសំរាប់ជួលលំនៅដ្ឋានបណ្ដោះអាសន្នដើម្បីរស់នៅ ឬក៏បង្ហាញថាដំណោះស្រាយធានារ៉ាប់រងនេះត្រូវបានពន្យាពេលយូរជាង ៣0ថ្ងៃពីពេលដែលបេក្ខជនបានដាក់ពាក្យទាមទារនោះទេ ។ ជាលទ្ធផល ការប្ដឹងឧទ្ធរណ៍របស់បេក្ខជនត្រូវបានគេបដិសេធចោល ហើយបេក្ខជននោះមិនមានសិទ្ធិសំរាប់ទទួលជំនួយ សំរាប់ជួលលំនៅដ្ឋានពី FEMA ទេ ។

**INO – ភាពគ្មានសិទ្ធិ – មិនមែនជាអ្នកតាំងទីលំនៅស្របច្បាប់:** ទំរង់បែបបទចេញផ្សាយ និងប្រកាសដែលបានចុះហត្ថលេខា ( ៩0 - ៦៩ B) គឺពិតជាត្រូវការ មុន FEMA អាចធ្វើការពិចារណាលើសិទ្ធិទទួលជំនួយរបស់បេក្ខជន ។ យោងតាមកំណត់ត្រារបស់យើង បេក្ខជនមិនបានបង្ហាញថា គាត់ ឬ សមាជិកណាម្នាក់នៅក្នុងគេហដ្ឋានរបស់គាត់ មានសញ្ជាតិអាមេរិក ជាជនជាតិដែលមិនមានសញ្ជាតិដើម ឬជាជនបរទេសដែលមានការបញ្ជាក់ច្បាស់លាស់ ។ ជាលទ្ធផល បេក្ខជនគ្មានសិទ្ធិទទួលជំនួយពី FEMA ទេ ។

**INO – ភាពគ្មានសិទ្ធិ – សិទ្ធិកាន់កាប់ដែលមិនបានបង្ហាញ:** កំណត់ត្រារបស់យើងបង្ហាញថា បេក្ខជនមិនបានបង្ហាញថាគាត់មានលំនៅដ្ឋាននៅពេលមានគ្រោះមហន្តរាយ ។ ជាលទ្ធផល បេក្ខជននោះគ្មានសិទ្ធិសុំជំនួយ សំរាប់ជួលជុលលំនៅដ្ឋាន ឬសំរាប់ផ្លាស់ទីលំនៅ ។

**INONV – ភាពគ្មានសិទ្ធិ – អំឡុងពេលកាន់កាប់មិនមានការបញ្ជាក់ច្បាស់លាស់:** នៅពេលបេក្ខជនដាក់ពាក្យសុំជំនួយ បេក្ខជនរូបនោះបានជំរាបមក FEMA ថា លំនៅដ្ឋានដែលទទួលរងការខូចខាតដោយគ្រោះមហន្តរាយ គឺជាកន្លែងដែលគាត់បានរស់នៅអស់រយៈពេលជាច្រើនឆ្នាំហើយ ។ នៅពេលមានការត្រួតពិនិត្យពី FEMA បេក្ខជនមិនអាចផ្ដល់ព័ត៌មានណាដែលបង្ហាញថា គេហដ្ឋានដែលយើងបានត្រួតពិនិត្យ គឺជាកន្លែងដែលគាត់បានរស់នៅ ។ បេក្ខជនមិនមានសិទ្ធិទទួលជំនួយលំនៅដ្ឋានពី FEMA ទេ រហូតទាល់តែយើងអាចបញ្ជាក់បានថា បេក្ខជននេះពិតជាបានរស់នៅឯអាសយដ្ឋានដែលបានផ្ដល់ឱ្យ ។

**INR – ភាពគ្មានសិទ្ធិ – នឹងមិនធ្វើការផ្លាស់ប្តូរទីលំនៅ:** យោងតាមកំណត់ត្រារបស់ FEMA បេក្ខជនបានប្រាប់ទៅអធិការកិច្ចរបស់ FEMA ថាគាត់នឹងមិនរើពីទីលំនៅដែលទទួលរងការខូចខាតរបស់គាត់ ខណៈពេលដែលការជួសជុលកំពុងដំណើរការ ។ ពីព្រោះបេក្ខជនមិនមានគំរោងធ្វើការផ្លាស់ប្តូរទីលំនៅ គាត់មិនមានសិទ្ធិសំរាប់សុំជំនួយសំរាប់ជួល ពី FEMA ទេនៅពេលនេះ ។

**INS – ភាពគ្មានសិទ្ធិ – ត្រូវបានទទួលការធានា (ដោយគ្មានការត្រួតពិនិត្យ):** យោងតាមកំណត់ត្រារបស់យើង គេហដ្ឋានដែលបេក្ខជនបានរស់នៅ នៅពេលដែលមានគ្រោះមហន្តរាយ គឺត្រូវបានរួមបញ្ចូលនៅក្នុងការធានារ៉ាប់រង ។ ការខូចខាតទាំងឡាយណាដែលត្រូវបានរាយការណ៍នៅពេលដាក់ពាក្យសុំជំនួយពី FEMA គួរតែត្រូវបានរួមបញ្ចូលនៅក្នុងការធានារ៉ាប់រងរបស់បេក្ខជន ។ FEMA មិនអាចផ្តល់ជំនួយដែលអាចរកបានពីប្រភពដទៃ រួមទាំងការធានារ៉ាប់រងផងដែរ ដូច្នេះ បេក្ខជនមិនមានសិទ្ធិទទួលជំនួយជួសជុលគេហដ្ឋាន ឬផ្លាស់ប្តូរលំនៅដ្ឋានពី FEMA នៅពេលនេះទេ ។ បេក្ខជនគួរតែដាក់ពាក្យទាមទារទៅទីភ្នាក់ងារធានារ៉ាប់រងឱ្យបានឆាប់ដូចដែលអាចធ្វើទៅបាន ពីព្រោះ FEMA អាចជួយជាមួយនឹងការបាត់បង់នានា ដែលមិនត្រូវបានរួមបញ្ចូលនៅក្នុងការធានារ៉ាប់រង ។

**IOVR – ភាពគ្មានសិទ្ធិ – លើសពីចំនួនអតិបរមារបស់កម្មវិធី:** យោងតាមកំណត់ត្រារបស់ FEMA ចំនួនអតិបរមានៃជំនួយហិរញ្ញវត្ថុរបស់ FEMA ត្រូវបានផ្តល់ឱ្យរួចជាស្រេចទៅបេក្ខជនសំរាប់តម្រូវការលំនៅដ្ឋាន និង តម្រូវការគ្រោះមហន្តរាយផ្សេងទៀត ។ ជាលទ្ធផល បេក្ខជនមិនមានសិទ្ធិទទួល នូវជំនួយហិរញ្ញវត្ថុបន្ថែមពី FEMA ទេ ។

**ISC – ភាពគ្មានសិទ្ធិ – សហគមន៍ដែលមានការអនុញ្ញាតច្បាស់លាស់នៅក្នុង SFHA:** យោងតាមកំណត់ត្រារបស់ FEMA គេហដ្ឋាននេះបានទទួលរងការខូចខាតដោយទឹកជំនន់ ហើយមានទីតាំងនៅក្នុងតំបន់រងគ្រោះដោយទឹកជំនន់ ដែលមានទីតាំងនៅក្នុងសហគមន៍មួយដែលមិនបានកំពុងចូលរួមក្នុងកម្មវិធីធានារ៉ាប់រងដោយគ្រោះទឹកជំនន់របស់ជាតិ ។ ពីព្រោះគេហដ្ឋានដែលរងគ្រោះដោយទឹកជំនន់ មិនមានទីតាំងនៅក្នុងតំបន់ដែលរងគ្រោះដោយទឹកជំនន់ ហើយសហគមន៍របស់បេក្ខជនមិនកំពុងចូលរួមនៅក្នុងកម្មវិធីធានារ៉ាប់រង

គ្រោះទឹកជំនន់ជាតិ FEMA មិនត្រូវបានគេអនុញ្ញាតឱ្យផ្តល់នូវជំនួយសំរាប់ធ្វើការជួសជុល និងសំរាប់ផ្លាស់ទីលំនៅនៅពេលនេះទេ ។

**NCOMP – ការមិនគោរពតាមតម្រូវការនៃការធានារ៉ាប់រងគ្រោះទឹកជំនន់:** យោងតាមកំណត់ត្រារបស់ FEMA បេក្ខជនមានតម្រូវការក្នុងការរក្សាទុកការគាំពារដោយការធានារ៉ាប់រងគ្រោះទឹកជំនន់លើទ្រព្យសម្បត្តិ ។ ដោយសារតែគេហដ្ឋានត្រូវបានទទួលរងនូវការខូចខាតដោយទឹកជំនន់ ហើយបេក្ខជនមិនមានគោលនយោបាយធានារ៉ាប់រងគ្រោះទឹកជំនន់ ដែលមាននៅលើបញ្ជីឯកសារជាមួយកម្មវិធីធានារ៉ាប់រងគ្រោះទឹកជំនន់ជាតិ FEMA មិនអាចផ្តល់ជំនួយសំរាប់ជួសជុល និងផ្លាស់ប្តូរទីលំនៅ នៅពេលនេះបានទេ ។ ប៉ុន្តែទោះបីជាយ៉ាងនេះក្តី FEMA អាចផ្តល់ជំនួយសំរាប់ជួល ប្រសិនអ្នកត្រួតពិនិត្យកំណត់ថា គេហដ្ឋាន នេះមិនមានសុវត្ថិភាព ហើយបេក្ខជនត្រូវការផ្លាស់ប្តូរទីតាំង ខណៈពេលការជួសជុលកំពុងដំណើរការ ។

**WVO – ត្រូវបានដក – បេក្ខជនធ្វើការដកដោយស្ម័គ្រចិត្ត:** យោងតាមកំណត់ត្រារបស់ FEMA បេក្ខជនបានបង្ហាញថា គាត់មិនត្រូវការជំនួយពី FEMA ទេ ។ ជាលទ្ធផល ពាក្យស្នើសុំជំនួយសំរាប់គ្រោះមហន្តរាយរបស់ FEMA ត្រូវបានដក ។

## 2. ការសំរេចចិត្តក្នុងការស្នើសុំ

**A-I69B – ការប្តឹងឧទ្ធរណ៍ – ការចុះហត្ថលេខាដែលមិនបានទទួល (៩០ - ៦៩ B):** យោងតាមកំណត់ត្រារបស់ FEMA គ្មានទំរង់បែបបទចេញផ្សាយ និងប្រកាសដែលមានចុះហត្ថលេខា (៩០ - ៦៩ B) ណាមួយមាននៅក្នុងឯកសារសំរាប់បេក្ខជនទេ ។ FEMA អាចផ្តល់ត្រឹមតែជំនួយប៉ុណ្ណោះ ប្រសិនទំរង ៩០ - ៦៩ B ត្រូវបានចុះហត្ថលេខា ចុះកាលបរិច្ឆេទ ហើយមាននៅក្នុងបញ្ជីឯកសារ ។

**A-IAW – ការប្តឹងឧទ្ធរណ៍ - គ្មានសិទ្ធិ - អាសយដ្ឋានដូចគ្នា:** នៅក្នុងលិខិតកាលពីលើកមុន យើងបានពន្យល់ថា កំណត់ត្រារបស់យើងបានបង្ហាញថា នៅពេលមានគ្រោះមហន្តរាយ បេក្ខជនបានកំពុងរស់នៅកន្លែងដែលមាន អាសយដ្ឋានដូចគ្នា និងអ្នកដែលបានដាក់ពាក្យសុំជំនួយលំនៅដ្ឋានពី FEMA ។ FEMA បានធ្វើការត្រួតពិនិត្យ ការប្តឹងឧទ្ធរណ៍នោះ និងឯកសារដែលបានផ្តល់ឱ្យហើយ FEMA នៅតែមិនអាចបញ្ជាក់

ថាបេក្ខជនបានរស់នៅ កន្លែងដែលមានអាសយដ្ឋានផ្សេងគ្នា ជាងអ្នកដែលបានដាក់ពាក្យរួចហើយ ។ ជាលទ្ធផល ការប្តឹងឧទ្ធរណ៍ នេះមិន ត្រូវបានគេយល់ព្រម ហើយបេក្ខជនមិនមានសិទ្ធិទទួលជំនួយលំនៅដ្ឋានពី FEMA ទេ ។

**A-IID – ការប្តឹងឧទ្ធរណ៍ – គ្មានសិទ្ធិ – ការខូចខាតតិចតួច – ម្ចាស់:** នៅក្នុងលិខិតកាលពីលើកមុន យើងបាន ពន្យល់ថា បេក្ខភាពមិនមានសិទ្ធិសុំជំនួយលំនៅដ្ឋានពី FEMA ទេ ពីព្រោះនៅពេល FEMA ធ្វើការត្រួត ពិនិត្យគេហដ្ឋាន វាបានកំណត់ថាគ្រោះមហន្តរាយមិនបានធ្វើឱ្យគេហដ្ឋានរបស់បេក្ខជនមិនមាន សុវត្ថិភាពនឹង រស់នៅក្នុងនោះ ។ ការកំណត់នេះគឺអាស្រ័យទៅលើការខូចខាតដែលបង្កឡើងដោយ គ្រោះមហន្តរាយ ។ យើងបានធ្វើការពន្យល់ថា ទោះបីជាគ្រោះមហន្តរាយបានបង្កនូវការខូចខាតតិចតួចក្តី វាពិតជាត្រឹមត្រូវក្នុង ការសង្ឃឹមថាបេក្ខជន ឬម្ចាស់ទ្រព្យធ្វើការជួសជុលបញ្ហាទាំងនេះ ។ យើងបានធ្វើការ បកស្រាយនូវឯកសារ ដែលអាចត្រូវបានគេដាក់បញ្ជូនដើម្បីបង្ហាញថា ការខូចខាតដល់លំនៅដ្ឋានគឺត្រូវបាន បង្កឡើងដោយគ្រោះមហន្តរាយ ហើយដែលបានបង្កឱ្យមានស្ថានភាពពិបាករស់នៅ និងគ្មានសុវត្ថិភាព ។ យើងបានពិនិត្យមើលនូវ ការប្តឹងឧទ្ធរណ៍នេះ ហើយបានកំណត់ថា ការសំរេចចិត្តលើកដំបូងរបស់យើង គឺត្រឹមត្រូវ ។ គេហដ្ឋាននេះមិនបាន ទទួលរងការខូចខាតដែលបង្ករដោយគ្រោះមហន្តរាយដែលធ្វើឱ្យវា មិនមានសុវត្ថិភាពសំរាប់បេក្ខជនសំរាប់រស់នៅ ។

**A-IIDV – ការប្តឹងឧទ្ធរណ៍ – ភាពគ្មានសិទ្ធិ – ការផ្ទៀងផ្ទាត់មើលអត្តសញ្ញាណដែលបានបាត់បង់:** នៅក្នុងលិខិត កាលពីមុន យើងបានពន្យល់ថា យើងត្រូវការព័ត៌មានបន្ថែមដើម្បីបញ្ជាក់អំពីអត្តសញ្ញាណ របស់បេក្ខជន មុនយើងអាចធ្វើការពិចារណាការដាក់ពាក្យសុំជំនួយសំរាប់គ្រោះមហន្តរាយ ។ FEMA ត្រូវបានគេតម្រូវឱ្យ ពិនិត្យមើលព័ត៌មានដែលមាននៅលើពាក្យសុំ ហើយយើងមិនអាចតម្រូវឱ្យដូចគ្នា នូវឈ្មោះ របស់បេក្ខជន និង លេខសុវត្ថិភាពសង្គម ដើម្បីធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណបាននោះទេ ។ យើង ធ្វើការពិពណ៌នាឯកសារដែល អាចផ្តល់នូវការត្រួតពិនិត្យដែលចាំបាច់ណាមួយ ។ FEMA មិនអាចផ្តល់ជំនួយ ទៅបុគ្គលណាម្នាក់ដោយមិន បានធ្វើការពិនិត្យអំពីអត្តសញ្ញាណរបស់អ្នកនោះឡើយ ។ ជាលទ្ធផល ការប្តឹង ឧទ្ធរណ៍មិនត្រូវឯកភាព ហើយ យើងមិនអាចដំណើរការការដាក់ពាក្យសុំតទៅទៀតនៅពេលនេះបានទេ ។

**A-IMI - ការប្តឹងឧទ្ធរណ៍ – ភាពគ្មានសិទ្ធិ – ការត្រួតពិនិត្យដែលមិនបានធ្វើ:** នៅក្នុងលិខិតកាលពីមុន យើងបានពន្យល់ថា ដើម្បីឱ្យគេពិចារណាសំរាប់ជំនួយលំនៅដ្ឋាន បេក្ខជន (ឬសមាជិកនៅក្នុងគេហដ្ឋានណាម្នាក់ដែលមានអាយុលើស ១៨ឆ្នាំ) ត្រូវជួបជាមួយអ្នកត្រួតពិនិត្យដើម្បីធ្វើការវាយតម្លៃការខូចខាតលំនៅដ្ឋានដែលបង្កដោយគ្រោះមហន្តរាយ ហើយយើងក៏បានពន្យល់ផងដែរថា កំណត់ត្រារបស់យើងបានបង្ហាញថា បេក្ខជនមិនបានរក្សាការណាត់ជួបជាមួយអធិការកិច្ចរបស់ FEMA ។ បេក្ខជនបានធ្វើការទាក់ទងមកកាន់បណ្តាញទូរស័ព្ទរបស់យើង ហើយអ្នកត្រួតពិនិត្យម្នាក់ទៀតត្រូវបានគេចាត់តាំងឱ្យធ្វើការវាយតម្លៃគេហដ្ឋាន ។ ជាថ្មីម្តងទៀត បេក្ខជននៅតែមិនរក្សាបាននូវការណាត់ជួប ។ ជាលទ្ធផល យើងមិនអាចជួយបេក្ខជននោះតទៅទៀតបានទេ ។

**A-INCI – ការប្តឹងឧទ្ធរណ៍ – ភាពគ្មានសិទ្ធិ – គ្មានការត្រួតពិនិត្យលើទំនាក់ទំនង:** នៅក្នុងលិខិតកាលពីមុន FEMA បានពន្យល់ថា ដើម្បីឱ្យគេពិចារណាសំរាប់ជំនួយលំនៅដ្ឋាន បេក្ខជន ឬសមាជិកនៅក្នុងលំនៅដ្ឋានណាម្នាកដែលមានអាយុលើស ១៨ឆ្នាំ) ត្រូវជួបជាមួយត្រួតពិនិត្យ ដើម្បីធ្វើការវាយតម្លៃការខូចខាតលំនៅដ្ឋាន ដែលបង្កដោយគ្រោះមហន្តរាយ ហើយយើងក៏បានពន្យល់ផងដែរថា អ្នកត្រួតពិនិត្យរបស់ FEMA មិនអាច ទាក់ទងបេក្ខជនដើម្បីកំណត់ពេលវេលាសំរាប់ណាត់ជួបបានទេ ។ បេក្ខជនបានទាក់ទងមកកាន់បណ្តាញទូរស័ព្ទរបស់ FEMA ហើយអ្នកត្រួតពិនិត្យម្នាក់ទៀតត្រូវបានគេចាត់តាំងឱ្យធ្វើការវាយតម្លៃគេហដ្ឋាន ។ ក្រោយពីមានការព្យាយាមជាបន្តបន្ទាប់មក អ្នកត្រួតពិនិត្យម្នាក់នោះមិនអាចធ្វើការទំនាក់ទំនងទៅបេក្ខជនដើម្បីកំណត់ពេល វេលាសំរាប់ធ្វើការត្រួតពិនិត្យ ។ ជាលទ្ធផល យើងនឹងមិនជួយបេក្ខជននេះលើសពីនោះទៀតទេ ។

**A-INFI - ការប្តឹងឧទ្ធរណ៍ – ភាពគ្មានសិទ្ធិ – ការទូទាត់លើការធានារ៉ាប់រងគ្រោះទឹកជំនន់ដែលខ្វះ ឬលិខិតបដិសេធ:** នៅក្នុងលិខិតកាលពីមុន យើងបានពន្យល់ថា បេក្ខជនមិនមានសិទ្ធិសំរាប់ជំនួយជួសជុល គេហដ្ឋានឬសំរាប់ផ្លាស់ប្តូរទីលំនៅ ពីព្រោះបេក្ខជនមានការធានារ៉ាប់រងគ្រោះទឹកជំនន់ ។ យើងបានធ្វើការ ពិពណ៌នាឯកសារដែលអាចត្រូវបានបញ្ជូនទៅសុំការសំរេចចិត្ត ។ យើងបានត្រួតពិនិត្យលើការអំពាវនាវរបស់ បេក្ខជន និងឯកសារបន្ថែមដែលបានផ្តល់ជូន ហើយយើងនៅតែមិនអាចបញ្ជាក់អំពីចំនួននៃការទូទាត់លើការ ធានារ៉ាប់រងរបស់បេក្ខជន ។ ជាលទ្ធផល ការប្តឹងឧទ្ធរណ៍ នេះមិនត្រូវបានឯកភាព ហើយបេក្ខជនមិនមានសិទ្ធិ សំរាប់ទទួលជំនួយលំនៅដ្ឋានពី FEMA ។

**A-INI, A-INS – ការប្តឹងឧទ្ធរណ៍ – គ្មានសិទ្ធិ – ការទូទាត់លើការធានារ៉ាប់រងគ្រោះទឹកជំនន់ដែលខ្វះ ឬលិខិតបដិសេធ:** នៅក្នុងលិខិតកាលពីមុន យើងបានពន្យល់ថា បេក្ខជនមិនមានសិទ្ធិសំរាប់ជំនួយជួសជុលគេហដ្ឋាន ឬសំរាប់ផ្លាស់ប្តូរទីលំនៅ ពីព្រោះបេក្ខជនមានការធានារ៉ាប់រងគ្រោះទឹកជំនន់ ។ លិខិតនេះក៏បានពិពណ៌នាផងដែរនូវឯកសារដែលបេក្ខជនអាចផ្ញើទៅសុំការសំរេចចិត្ត ។ យើងបានត្រួតពិនិត្យឯកសារដែលបេក្ខជនបានឱ្យ ហើយយើងមិនអាចដំណើរការការស្នើរសុំនោះបានទេ ពីព្រោះយើងមិនបានទទួលឯកសារពិស្តារអំពីការទូទាត់លើការធានារ៉ាប់រង ឬលិខិតបដិសេធការធានារ៉ាប់រងណាមួយឡើយ ។ ប្រសិនបេក្ខជនមាន សំណួរទាក់ទងដល់ឯកសារចាំបាច់នោះ ពួកគេគួរតែទាក់ទងមកបណ្តាញទូរស័ព្ទរបស់ FEMA ។

**A-INO - ការប្តឹងឧទ្ធរណ៍ – ភាពគ្មានសិទ្ធិ – ក្រោយពេលកំណត់ ៦០ថ្ងៃ:** នៅក្នុងលិខិតកាលពីមុន យើងបានពន្យល់ថា ការសុំការសំរេចចិត្តរបស់ FEMA ត្រូវដាក់បញ្ជូនក្នុងរវាង ៦០ ថ្ងៃនៃលិខិតបង្ហាញពីសំរេចចិត្ត ។ បេក្ខជនមិនបានដាក់ពាក្យសុំក្រោយពេល៦០ថ្ងៃនៃកាលបរិច្ឆេទកំណត់ ។ ជាលទ្ធផល ការប្តឹងឧទ្ធរណ៍នេះនឹងមិនត្រូវបានគេធ្វើការពិចារណាលុះត្រាតែល័ក្ខខ័ណ្ឌមួយក្នុងចំណោមលក្ខខ័ណ្ឌខាងក្រោមបានរារាំងបេក្ខជនពីការបំពេញការស្នើរសុំ: ១. ការព្យាបាលជំងឺនៅមន្ទីរពេទ្យ ជំងឺ ភាពអសមត្ថភាព ការទទួលមរណភាពរបស់សមាជិកគ្រួសារ, ២. ការធ្វើដំណើរជាលក្ខណៈបុគ្គល ឬក្នុងគោលបំណងអាជីវកម្ម ដែលធ្វើឱ្យបេក្ខជនមិនបានស្ថិតនៅក្នុងតំបន់នោះនៅក្នុងអំឡុងពេលការប្តឹងឧទ្ធរណ៍ ។ ប្រសិនបេកជនចង់ឱ្យ FEMA ពិចារណាការស្នើសុំ បេក្ខជនអាចផ្ញើរលិខិតពន្យល់ ព្រមទាំងឯកសារពាក់ព័ន្ធទាំងអស់ដែលអាចបង្ហាញយ៉ាងច្បាស់ថាហេតុអ្វីបេក្ខជនមិនបានបំពេញការប្តឹងឧទ្ធរណ៍នោះ ។

**A-INO - ការប្តឹងឧទ្ធរណ៍ – គ្មានសិទ្ធិ – ការទូទាត់លើការធានារ៉ាប់រងលើសពីការខូចខាតដែលសមស្របរបស់ FEMA:** មិនដូចជាការធានារ៉ាប់រងឯកជនទេ កម្មវិធីផ្តល់ជំនួយសំរាប់ជួសជុលលំនៅដ្ឋានរបស់ FEMA គឺ ត្រូវបានកំណត់ត្រឹមតែការជួសជុលណាដែលចាំបាច់ប៉ុណ្ណោះ ។ ជាលទ្ធផល វាជារឿងធម្មតាទេសំរាប់ការទូទាត់លើការធានារ៉ាប់រងដែលលើសពីអ្វីដែល FEMA អាចផ្តល់ឱ្យសំរាប់ការជួសជុល ។ ពីព្រោះ FEMA មិនអាចផ្តល់ឱ្យជាច្រើនដងនូវជំនួយដែលផ្តល់ឱ្យដោយការធានារ៉ាប់រងនោះ ការប្តឹងឧទ្ធរណ៍ របស់បេក្ខជនមិនត្រូវបានឯកភាព ។

---

**A-INO – ការប្តឹងឧទ្ធរណ៍ – ភាពគ្មានសិទ្ធិ – មិនមែនជាអ្នកតាំងទីលំនៅស្របច្បាប់:** នៅក្នុងលិខិតកាលពីមុន យើងបានពន្យល់ថា FEMA មិនអាចធ្វើការពិចារណាបេក្ខជនសំរាប់ជំនួយដែលពួកគេមានសិទ្ធិទទួលរហូតទាល់តែពួកគេបង្ហាញលើទំរង់បែបបទចេញផ្សាយ និងប្រកាស (៩០-៦៩B) ថាពួកគេ ឬសមាជិកនៅក្នុងផ្ទះរបស់ពួកគេមានមានសញ្ជាតិអាមេរិក ឬជនបទេសដែលមានការបញ្ជាក់ត្រឹមត្រូវ ។ យើងក៏សំណូមពរឱ្យបេក្ខជនបំពេញ និងដាក់ពាក្យស្នើរសុំ ។ យើងបានធ្វើការពិនិត្យមើលការស្នើរសុំរបស់ បេក្ខជន និងឯកសារបន្ថែមផ្សេងៗដែលត្រូវបានផ្តល់ឱ្យ ហើយយើងនៅតែមិនអាចកំណត់ថាបេក្ខជន ឬសមាជិកណាម្នាក់ដែលរស់នៅក្នុងលំនៅដ្ឋានរបស់ពួកគេមានសញ្ជាតិអាមេរិក ឬជាជនបរទេសដែលមាន ការបញ្ជាក់ត្រឹមត្រូវបានឡើយ ។ ជាលទ្ធផល ការប្តឹងឧទ្ធរណ៍ របស់បេក្ខជនត្រូវបាន បដិសេធចោល ហើយពួកគេនឹងមិនត្រូវបានគេពិចារណាសំរាប់ជំនួយ FEMA ឡើយ ។

**A-INO - ការប្តឹងឧទ្ធរណ៍ – ភាពគ្មានសិទ្ធិ – សិទ្ធិកាន់កាប់ដែលគ្មានការបញ្ជាក់:** នៅក្នុងលិខិតកាលពីមុនយើងបានពន្យល់ថា បេក្ខជនមិនបានបង្ហាញថាខ្លួនជាម្ចាស់លំនៅដ្ឋាននៅពេលមានគ្រោះមហន្តរាយ ។ យើងបានធ្វើការពិពណ៌នាឯកសារដែលបេក្ខជនអាចដាក់បញ្ជូនមក ដែលបង្ហាញពីសិទ្ធិកាន់កាប់លំនៅដ្ឋានដែលបានទទួលរងនូវការខូចខាត ។ យើងបានពិនិត្យលើការស្នើរសុំរបស់បេក្ខជន និងឯកសារផ្សេងៗដែលបានផ្តល់ឱ្យ តែទោះបីជាយ៉ាងនេះក្តី យើងនៅតែមិនអាចបញ្ជាក់ថាបេក្ខជនពិតជាម្ចាស់កម្មសិទ្ធិនៃលំនៅដ្ឋាននោះប្រាកដមែន ។ ជាលទ្ធផល ការប្តឹងឧទ្ធរណ៍ នោះត្រូវបានគេបដិសេធហើយបេក្ខជននោះមិនមានសិទ្ធិទទួលជំនួយសំរាប់ជួសជុល ឬផ្លាស់ប្តូរលំនៅដ្ឋាន ។

**A-INO - ការប្តឹងឧទ្ធរណ៍ – ភាពគ្មានសិទ្ធិ – មិនអាចសងវិញចំពោះអត្រាថ្លៃជួលដែលបានអនុម័ត:** កាលពីមុន យើងបានពន្យល់ថា ចំនួននៃជំនួយថ្លៃឈ្នួលប្រចាំខែរបស់ FEMA គឺអាស្រ័យទៅលើចំនួនបន្ទប់ដែលបានប្រើប្រាស់នៅពេលមានគ្រោះមហន្តរាយ ហើយត្រូវបានកំណត់ចំពោះអត្រាថ្លៃជួលដែលកំណត់ដោយ FEMA និងក្រសួងលំនៅដ្ឋាន និងអភិវឌ្ឍន៍ជនបទ (U.S. Department of Housing and Urban Development – HUD) ។ យើងបានធ្វើការត្រួតពិនិត្យ ការប្តឹង ឧទ្ធរណ៍របស់បេក្ខជន និងព័ត៌មានដែលបានផ្តល់ឱ្យ ។ យើងបានកំណត់ថា អត្រាប្រាក់ប្រចាំខែដែលយើងបាន ទូទាត់ទៅឱ្យបេក្ខជន គឺជាចំនួនដែលសមស្រប ។ ជាលទ្ធផល ការប្តឹងឧទ្ធរណ៍ នេះត្រូវបានបដិសេធ ហើយ យើងមិនអាចទូទាត់អត្រាថ្លៃឈ្នួលប្រចាំខែខ្ពស់ជាងនេះបាននោះទេ ។

**A-INONV - ការប្តឹងឧទ្ធរណ៍ – ភាពគ្មានសិទ្ធិ – កំឡុងពេលកាន់កាប់មិនមានការបញ្ជាក់ច្បាស់លាស់:** នៅក្នុងលិខិតកាលពីលើកមុន យើងបានពន្យល់ថា យើងអាចបញ្ជាក់ថា គេហដ្ឋានដែលបេក្ខជនបានរាយការណ៍មកថា ត្រូវបានទទួលរងដោយគ្រោះមហន្តរាយនោះ គឺស្ថិតនៅចំកន្លែងដែលគាត់ធ្លាប់បានរស់នៅ ។ យើងបាន ពិនិត្យការប្តឹងឧទ្ធរណ៍ និងឯកសារដទៃទៀតរបស់បេក្ខជន ហើយយើងមិនទាន់អាចបញ្ជាក់បានថា គេហដ្ឋានដែលបេក្ខជនបានរាយការណ៍នោះពិតជាស្ថិតនៅកន្លែងដែលគាត់ធ្លាប់បានរស់នៅឬអត់ ។ ជាលទ្ធផល ការប្តឹងឧទ្ធរណ៍ របស់បេក្ខជនមិនត្រូវបានគេឯកភាព ហើយពួកគាត់គ្មានសិទ្ធិទទួលជំនួយលំនៅដ្ឋានពី FEMA ទេ ។

**A-IOVR - ការប្តឹងឧទ្ធរណ៍ – ភាពគ្មានសិទ្ធិ – លើសពីចំនួនអតិបរមារបស់គំរោង:** នៅក្នុងលិខិតកាលពីមុន យើងបានពន្យល់ថា បេក្ខជនមិនមានសិទ្ធិទទួលជំនួយបន្ថែមពី FEMA ទេ ពីព្រោះចំនួនអតិបរមានៃជំនួយហិរញ្ញវត្ថុរបស់ FEMA ត្រូវបានផ្តល់ជូនរួចហើយសំរាប់តម្រូវការលំនៅដ្ឋាន និងតម្រូវការនានា ។ យើងបាន ពិនិត្យការស្នើរសុំ និងឯកសារបន្ថែមដែលបានផ្តល់ឱ្យ ។ កំណត់ត្រារបស់យើងបានបង្ហាញថា បេក្ខជនបាន ឈានទៅដល់ចំនុចកំណត់នៃជំនួយហិរញ្ញវត្ថុរបស់ FEMA ហើយ ។ ដូចនេះ យើងមិនអាចផ្តល់នូវជំនួយ បន្ថែមពី FEMA ដល់បេក្ខជនតទៅទៀតទេ ។

**A-ISC - ការប្តឹងឧទ្ធរណ៍ – ភាពគ្មានសិទ្ធិ - សហគមន៍ដែលមានការអនុញ្ញាតច្បាស់លាស់នៅក្នុង SFHA:** នៅក្នុងលិខិតកាលពីមុន យើងបានពន្យល់ថាបេក្ខជនមិនមានសិទ្ធិសំរាប់ជំនួយជួសជុលលំនៅដ្ឋាន ឬសំរាប់ផ្លាស់ទីលំនៅពី FEMA ទេ ពីព្រោះលំនៅដ្ឋាននេះស្ថិតនៅក្នុងតំបន់ទឹកជំនន់នៅក្នុងសហគមន៍មួយដែលមិន កំពុងចូលរួមនៅក្នុងកម្មវិធីធានារ៉ាប់រងគ្រោះទឹកជំនន់ជាតិ (NFIP) ។ លិខិតនោះក៏បានធ្វើការពិពណ៌នា ផងដែរនូវឯកសារដែលបេក្ខជនអាចផ្ញើរទៅសុំការសំរេចចិត្ត ។ យើងបានពិនិត្យលើការប្តឹងឧទ្ធរណ៍ និង ឯកសារផ្សេងៗទៀត ។ កំណត់ត្រារបស់យើងនៅតែបង្ហាញថា លំនៅដ្ឋានរបស់បេក្ខជនគឺមានទីតាំងនៅក្នុង តំបន់ទឹកជំនន់ ហើយលំនៅដ្ឋានរបស់គាត់នោះពិតជាទទួលរងការខូចខាតដោយទឹកជំនន់មែន ។ ជាលទ្ធផល ការប្តឹងឧទ្ធរណ៍ របស់គាត់ត្រូវបានបដិសេធចោល ហើយបេក្ខជនមិនមានសិទ្ធិសំរាប់ទទួលជំនួយលំនៅដ្ឋានពី FEMA ទេ ។

**A-NCOMP - ការប្តឹងឧទ្ធរណ៍ - ការមិនគោរពតាមតម្រូវការនៃការធានារ៉ាប់រងគ្រោះទឹកជំនន់:** នៅក្នុងលិខិតកាលពីមុន យើងបានពន្យល់ថា បេក្ខជនគ្មានសិទ្ធិទទួលជំនួយសំរាប់ការជួសជុលលំនៅដ្ឋាន ឬផ្លាស់ប្តូរទីលំនៅទេ ពីព្រោះពួកគាត់មិនបានរក្សារទុកនូវការធានារ៉ាប់រងគ្រោះទឹកជំនន់សំរាប់ទ្រព្យសម្បត្តិរបស់គេ ។ ពីព្រោះ យើងមិនបានទទួលឯកសារដើម្បីកំណត់ថា លំនៅដ្ឋានមិនបានទទួលរងការខូចខាតដោយគ្រោះទឹកជំនន់ ឬ/ហើយ យើងមិនបានទទួលឯកសារដែលបង្ហាញថាបេក្ខជនមិនមានគោលនយោបាយធានារ៉ាប់រងគ្រោះទឹកជំនន់ចំពោះទ្រព្យសម្បត្តិរបស់ពួកគេនោះ ការប្តឹងឧទ្ធរណ៍នេះនឹងត្រូវបានបដិសេធចោល ។

# គំរូ ~ សំណុំបែបបទ ៩០~៦៩B របស់ FEMA
# សេចក្តីប្រកាស និងការចេញផ្សាយ

| | |
|---|---|
| **ក្រសួងសន្តិសុខមាតុភូមិ**<br>**ទីភ្នាក់ងារគ្រប់គ្រងគ្រោះមហន្តរាយសហព័ន្ធ**<br>**សេចក្តីប្រកាស និងការចេញផ្សាយ** | O.M.B.No. 1660-0002<br>ផុតកំណត់ ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១០ |

**សេចក្តីប្រកាស និងការចេញផ្សាយ**

ដើម្បីមានសិទ្ធិសំរាប់ទទួលជំនួយគ្រោះមហន្តរាយពី FEMA សមាជិកនៅក្នុងផ្ទះត្រូវមានសញ្ជាតិដើមអាមេរិក ជនបរទេសសញ្ជាតិអាមេរិក ឬជនបរទេសរស់នៅក្នុងសហរដ្ឋអាមេរិកដែលមានការបញ្ជាក់ត្រឹមត្រូវ ។ **ចូរអានសំណុំបែបបទនេះដោយផ្ចិតផ្ចង់ ចុះហត្ថលេខា ហើយប្រគល់ទៅឱ្យអ្នកត្រួតពិនិត្យ ហើយបង្ហាញឱ្យគាត់ឃើញរូបថតបច្ចុប្បន្ន ។** សូមមកធ្វើការពិគ្រោះយោបល់ជាមួយមេធាវី ឬអ្នកជំនាញផ្នែកអន្តោប្រវេសន៍ ប្រសិនអ្នកមានសំណួរ ។

ខ្ញុំសូមអះអាង ដោយហ៊ានទទួលទោសពីបទសក្ខីភាពភាពទុច្ចរិត ថា (សូមជ្រើសរើស១):

- ☐ ខ្ញុំជាជនជាតិអាមេរិក ឬជនបរទេសមានសញ្ជាតិអាមេរិក ។
- ☐ ខ្ញុំជាជនបរទេសរស់នៅសហរដ្ឋអាមេរិកដែលមានការបញ្ជាក់ត្រឹមត្រូវ ។
- ☐ ចូរសរសេរឈ្មោះពេញ និងអាយុកូនដែលតូចជាងគេរបស់អ្នក: ខ្ញុំជាឪពុកម្តាយ ជាអាណាព្យាបាលរបស់ក្មេងដែលរស់នៅជាមួយខ្ញុំ ហើយដែលមានសញ្ជាតិដើមអាមេរិក ជនបរទេសសញ្ជាតិអាមេរិក ឬជនបរទេសរស់នៅក្នុងសហរដ្ឋអាមេរិកដែលមានការបញ្ជាក់ត្រឹមត្រូវ ។ ចូរសរសេរឈ្មោះពេញ និងអាយុកូនដែលតូចជាងគេរបស់អ្នក:______________________

**ខ្ញុំសូមបញ្ជាក់ដោយសូមភ្ជាប់ជាមួយនូវហត្ថលេខារបស់ខ្ញុំថា:**

* មានតែពាក្យសុំមួយប៉ុណ្ណោះបានដាក់សំរាប់លំនៅដ្ឋានរបស់ខ្ញុំ ។
* រាល់ព័ត៌មានទាំងអស់ដែលខ្ញុំបានបំពេញនៅក្នុងពាក្យស្នើសុំជំនួយគ្រោះមហន្តរាយពី FEMA ពិតជាត្រឹមត្រូវ និងសុក្រឹត ។
* ខ្ញុំនឹងប្រគល់ថវិកាសំរាប់ជំនួយគ្រោះមហន្តរាយដែលខ្ញុំបានទទួលពី FEMA ឬពីរដ្ឋ ប្រសិនខ្ញុំមានការធានារ៉ាប់រង ឬលុយផ្សេងទៀតសំរាប់ការខូចខាត ដូចគ្នា ឬប្រសិនខ្ញុំមិនប្រើប្រាស់ថវិកាជំនួយគ្រោះមហន្តរាយពី FEMA សំរាប់គោលបំណងដែលចាំបាច់ ។

**ខ្ញុំយល់ថា** ប្រសិនខ្ញុំធ្វើរបាយការណ៍មិនត្រឹមត្រូវដោយចេតនា ឬបិទបាំងព័ត៌មានដើម្បីទទួលជំនួយគ្រោះមហន្តរាយ នោះគឺជាការបំពានច្បាប់សហព័ន្ធ និងច្បាប់របស់រដ្ឋ ដែលត្រូវទទួលទោសតាមក្រមរដ្ឋប្បវេណី និងក្រមព្រហ្មទ័ណ្ឌកំរិតធ្ងន់ រួមទាំងការផាកពិន័យពី ២៥០.០០០ ដុល្លារឡើងទៅ ការជាប់ពន្ធនាគារ ឬទាំងពីរ (១៨ U.S.C. §§ ២៨៧, ១០០១, និង ៣៥៧១) ។

**ខ្ញុំយល់ថា** ព័ត៌មានដែលបានផ្តល់ឱ្យនៅក្នុងពាក្យសុំជំនួយគ្រោះមហន្តរាយពី FEMA អាចស្ថិតនៅក្រោមការគ្រប់គ្រង និងបែងចែកនៅក្នុងក្រសួងសន្តិសុខមាតុភូមិ (DHS) រួមមានការិយាល័យអន្តោប្រវេសន្ត និងគយ ។

**ខ្ញុំយល់ព្រមឱ្យ** FEMA ធ្វើការផ្ទៀងផ្ទាត់រាល់ព័ត៌មានទាំងអស់ដែលខ្ញុំបានផ្តល់ឱ្យអំពីទ្រព្យសម្បត្តិ ទីកន្លែងរស់នៅ ប្រាក់ចំណូល ការងារ កូនក្នុងបន្ទុក ដើម្បីធ្វើការកំណត់សិទ្ធិសមស្របរបស់ខ្ញុំសំរាប់ទទួលជំនួយគ្រោះមហន្តរាយ ហើយ

**ខ្ញុំយល់ព្រមឱ្យ**អ្នកមើលថែទ្រព្យសម្បត្តិ ឬឯកសារនៃការធានារ៉ាប់រងរបស់ខ្ញុំ និយោជក ភ្នាក់ងារឯកជន ឬសាធារណ: សេវកម្មទិន្នន័យឥណទាន ឬហិរញ្ញវត្ថុធនាគាចេញផ្សាយនូវព័ត៌មានទៅឱ្យ FEMA ឬរដ្ឋ ទៅតាមការស្នើសុំ ។

| | | | | |
|---|---|---|---|---|
| ឈ្មោះ | ហត្ថលេខា | | ថ្ងៃខែឆ្នាំកំណើត | កាលបរិច្ឆេទចុះហត្ថលេខា |
| ល.អត្ត.អ្នកត្រួតពិនិត្យ | ល.ពាក្យសុំរបស់ FEMA | | ល.គ្រោះមហន្តរាយ | |
| អាសយដ្ឋានទ្រព្យសម្បត្តិដែលរងការខូចខាត | | ទីក្រុង | រដ្ឋ | លេខកូដតំបន់ |

Form 90-69B – Declaration and Release – Khmer (Cambodian)

## សេចក្តីថ្លែងការណ៍អំពីលក្ខន្តិកៈឯកជន

លក្ខន្តិកៈស្តីអំពីជំនួយសង្គ្រោះបន្ទាន់សំរាប់គ្រោះមហន្តរាយ Robert T. Stafford, លេខ ៤២ U.S.C. §§ ៥១២១-៥២០៦ សេចក្តីបង្គាប់ប្រតិបត្តិលេខ ១២១៤៨, ដូចដែលបានធ្វើវិសោធនកម្មហើយ និង ជំពូកទី៤ នៃលក្ខន្តិកៈឆ្នាំ១៩៩៦ ស្តីអំពីការបង្រួបបង្រួមឱកាសការងារ និងការទទួលខុសត្រូវផ្ទាល់ខ្លួន លេខ ៨ U.S.C. §§ ១៦០១ ដែលអនុញ្ញាតឱ្យចេញផ្សាយព័ត៌មាននេះ។ ការប្រើប្រាស់ជាចំបងនូវព័ត៌មាននេះគឺដើម្បីកំណត់សិទ្ធិរបស់អ្នកក្នុងការទទួលជំនួយគ្រោះមហន្តរាយពី FEMA ។ ការរក្សាទុកភាពសម្ងាត់នៃព័ត៌មាននេះអាចធ្វើទៅបាន ដោយមានការស្នើសុំជាលាយលក្ខអក្សរ ទៅភ្នាក់ងារសហព័ន្ធ ឬភ្នាក់ងាររដ្ឋដែលផ្តល់ជំនួយគ្រោះមហន្តរាយនេះ ក៏ដូចជារដ្ឋាភិបាលក្នុងតំបន់ ឬទីភ្នាក់ងារស្ម័គ្រចិត្តពីអ្នកដែលអ្នកកំពុងសុំជំនួយ ដើម្បីឱ្យកិច្ចខិតខំសំរាប់ជំនួយនេះមិនត្រូវបានធ្វើច្រើនដង ឬទៅកាន់ភ្នាក់ងារនានា អង្គការ និងស្ថាប័នដែលចាំបាច់សំរាប់ FEMA ក្នុងការទទួលព័ត៌មានពីពួកគេ ដើម្បីធ្វើឱ្យមានការកំណត់សិទ្ធិត្រឹមត្រូវ ឬទៅកាន់ភ្នាក់ងាររបស់រដ្ឋាភិបាលប្រចាំតំបន់ រដ្ឋ ឬសហព័ន្ធដើម្បីលើកកំពស់ផែនការបន្ធូរបន្ថយគ្រោះថ្នាក់ដោយគ្រោះមហន្តរាយ ឬទៅកាន់ភ្នាក់ងារអនុវត្តច្បាប់ ឬអង្គការវិជ្ជាជីវៈ នៅកន្លែងណាដែលមានការបំពានច្បាប់ ឬទៅកាន់ភ្នាក់ងារសហព័ន្ធ ឬភ្នាក់ងាររដ្ឋ នៅពេលយើងស្នើសុំព័ត៌មានទាក់ទិនទៅនឹងការសំរេចចិត្តរបស់ទីភ្នាក់ងារពាក់ព័ន្ធនឹងការធានារ៉ាប់រងក្នុងការផ្តល់ជំនួយ ឬនៅក្នុងកាលៈទេសៈដែលភ្នាក់ងារសហព័ន្ធស្នើសុំព័ត៌មានសំរាប់គោលបំណងស្រដៀងគ្នាពីយើង ឬទៅកាន់ការិយាល័យព្រឹទ្ធសភា ដើម្បីឆ្លើយតបទៅនឹងសំណួរទៅតាមការស្នើសុំរបស់បុគ្គល ឬទៅកាន់ការិយាល័យគ្រប់គ្រង និងថវិកា (OMB) ពាក់ព័ន្ធទៅនឹងជំនួយសង្គ្រោះឯកជនតាមសារាចររបស់ OMB លេខ A-១៩ និងទៅកាន់ការិយាល័យគ្រប់គ្រងឯកសារជាតិ នៅក្នុងការត្រួតពិនិត្យការគ្រប់គ្រងឯកសារដែលធ្វើឡើងតាមការអនុញ្ញាតតាមសារាចរលេខ ៤៤ U.S. C. §§ ២៩០៤ និង ២៩០៦ លេខសម្ងាត់របស់អ្នកគឺត្រូវបានគេសួរក្នុងពេលចុះឈ្មោះ ដោយយោងទៅតាមលក្ខន្តិកៈឆ្នាំ១៩៩៦ ស្តីអំពីការកែលំអរការប្រមូលបំណុល លេខ ១៩៩៦, ៣១ U.S.C. §§ ៣៣២៥ (d) និង ៧៧០១ ©(១). ការផ្តល់នូវលេខសម្ងាត់ និងព័ត៌មានផ្សេងៗគឺធ្វើទៅតាមការស្ម័គ្រចិត្ត ប៉ុន្តែការមិនបានធ្វើដូចនេះអាចពន្យារ ឬរាំងស្ទះដល់ការផ្តល់ជំនួយគ្រោះមហន្តរាយ ។

## ការជូនដំណឹងអំពីការរក្សាភាពសម្ងាត់នៃឯកសារ

ខ្លឹមសារនៃការធ្វើសេចក្តីរាយការណ៍សំរាប់ពាក្យសុំនេះត្រូវបានគេប៉ាន់ប្រមាណត្រឹមតែរយៈពេល២នាទីជាមធ្យមសំរាប់ការឆ្លើយតបនីមួយៗ។ ខ្លឹមសារនេះរួមមានពេលវេលាសំរាប់ការពិនិត្យការណែនាំ ការប្រមូលទិន្នន័យ ការបំពេញពាក្យ និងដាក់ពាក្យ។ អ្នកមិនត្រូវបានគេតម្រូវឱ្យបំពេញព័ត៌មានទាំងនេះទេ លុះត្រាតែលេខត្រួតពិនិត្យ O.M.B. ដែលមានសុពលភាពត្រូវបានដាក់បង្ហាញនៅលើជ្រុងខាងលើនៃពាក្យស្នើសុំនេះ។ ចូរផ្ញើយោបល់របស់អ្នកទាក់ទិននិងសុក្រឹតភាពនៃខ្លឹមសារ និងសំណូមពរសុំកាត់បន្ថយបន្ទុកទៅដល់: ការិយាល័យផ្នែកប្រមូលព័ត៌មាន របស់ទីភ្នាក់ងារគ្រប់គ្រងគ្រោះមហន្តរាយរបស់សហព័ន្ធ របស់ក្រសួងសន្តិសុខមាតុភូមិ ដែលមានអាសយដ្ឋាន ផ្លូវលេខ ៥០០ C, SW, រដ្ឋវ៉ាស៊ីនតោន ឌីស៊ី ២០៤៧២, គំរោងកាត់បន្ថយការងារការិយាល័យ (១៦៦០-០០០២) ។

**កំណត់សំគាល់:** ចូរសូមកុំផ្ញើពាក្យដែលបានបំពេញហើយមកកាន់អាសយដ្ឋាននេះ។

**សំណុំបែបបទ FEMA ៩០-៦៩B ខែឧសភា ឆ្នាំ២០០៧ ជំនួសរាល់ការបោះពុម្ពកាលពីលើកមុន**

## ប្រសិនអ្នកសង្ស័យថាជនណាម្នាក់កំពុងធ្វើការដាក់
## ពាក្យប្តឹងទាមទារមិនពិតប្រាកដ
## ចូរទូរស័ព្ទមកកាន់បណ្តាញទូរស័ព្ទទទួលបន្ទុកផ្នែកកេង
## បន្លំរបស់ FEMA:

# 1-800-323-8603

## ចូរជួយឱ្យ FEMA មានការប្រាកដថា
## ជំនួយគ្រោះមហន្តរាយពិតជាបានដល់
## ដៃអ្នកដែលត្រូវទទួលតែប៉ុណ្ណោះ។
## វាជាការបំពានច្បាប់សហព័ន្ធ
## ទាំងស្រុងក្នុងការដាក់ពាក្យប្តឹងទាមទារមិនពិ
## តប្រាកដ។

ជំនួយរបស់ FEMA គឺអាចផ្តល់ចំពោះលំនៅដ្ឋាន ឬជនរងគ្រោះទាំងឡាយណាដែលបានបំពេញទៅតាមល័ក្ខខ័ណ្ឌនៃសិទ្ធិដែល
អាចទទួលបានតែប៉ុណ្ណោះ។ គ្មានអង្គភាពប្រចាំតំបន់ រដ្ឋ ឬសហព័ន្ធ ឬមន្ត្រី (ឬទីភាក់ងាររបស់ពួកគេណាម្នាក់)
អាចមានភាពរើសអើងលើបុគ្គលណាម្នាក់ ដោយសារតែជាតិសាសន៍ ពណ៌សម្បុរ សាសនា ភេទ អាយុ សញ្ជាតិកំណើត ពិការភាព
ឬស្ថានភាពសេដ្ឋកិច្ចនោះទេ។